## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

កាលបរិច្ឆេទឯកសារ៖ ១២ ខែ មីនា ឆ្នាំ២០១២

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ ភាសាបារាំង/ភាសាខ្មែរ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Mar-2012, 13:59
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ខ្លឹមសារជាក់លាក់ជាបឋមស្តីពីសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំ នាពេលសវនាការថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ជេត វណ្ណលី　មេធាវី គីម ម៉េងឃី

មេធាវី ហុង គីមសួន　មេធាវី ឡោ ជុនធី

មេធាវី ម៉ុច សុវណ្ណារី　មេធាវី ស៊ិន សុវ៉ន

មេធាវី សំ សុគង់　មេធាវី វ៉ែន ពៅ

មេធាវី ទី ស្រ៊ីនណា

មេធាវី Emmanuel ALTIT

**ដាក់ជូន៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

មេធាវី Pascal AUBOIN

មេធាវី Olivier BAHOUGNE

មេធាវី Patrick BAUDOIN

មេធាវី Evelyne BOILEAU-BRANDOMIR

មេធាវី Philippe CANONNE

មេធាវី Annie DELAHAIE

មេធាវី Laure DESFORGES

មេធាវី Ferdinand DJAMMEN NZEPA

មេធាវី Nicole DUMAS

មេធាវី Isabelle DURAND

មេធាវី Françoise GAUTRY

មេធាវី Marie GUIRAUD

មេធាវី Emmanuel JACOMY

មេធាវី Martine JACQUIN

មេធាវី Daniel LOSQ

មេធាវី Christine MARTINEAU

មេធាវី Madhev MOHAN

មេធាវី Barnabé NEKUIE

មេធាវី Lyma Thuy NGUYEN

មេធាវី Elisabeth RABESANDRATANA

មេធាវី Julien RIVET

មេធាវី Fabienne TRUSSES NAPROUS

មេធាវី Nushin SARKARATI

មេធាវី Philippine SUTZ

លោក យ៉េត ចរិយា

លោក William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្ដី៖**

មេធាវី សុន អរុណ

មេធាវី Michiel PESTMAN

មេធាវី Victor KOPPE

មេធាវី អាង ឧត្តម

មេធាវី Michael G. KARNAVAS

មេធាវី ផាត់ ពៅស៊ាង

មេធាវី Diana Ellis

មេធាវី គង់ សំអុន

មេធាវី Jacques VERGES

មេធាវី Arthur VERCKEN

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត៖**

មេធាវី Silke STUDZINSKY

## I. សេចក្តីផ្តើម និងសេចក្តីអង្កេតបឋម

១. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសេចក្តីសប្បាយរីករាយណាស់ ដែលមានឱកាសក្នុងការផ្តល់ជូនដល់អង្គជំនុំជម្រះនូវសេចក្តីបញ្ជាក់បន្ថែម ហើយដែលជាការបញ្ជាក់ទៅតាមការស្នើឡើងដោយអង្គជំនុំជម្រះបន្ទាប់ពីយើងខ្ញុំបានផ្តល់ការចង្អុលបង្ហាញដំបូង កាលពីថ្ងៃទី២៩ មិថុនា កន្លងទៅនេះ។ យើងខ្ញុំបានដឹងច្បាស់ជាងអ្នកណាៗទាំងអស់ អំពីសារៈសំខាន់នៃសំណងនៅក្នុងដំណើរការយុត្តិធម៌ ហើយប្រសិនបើសំណងមិនមែនជាគោលដៅចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមានតួនាទីអ្វីនៅក្នុងការជំនុំជម្រះនេះដែរ។ សំណង ជាចាំបាច់ត្រូវតែសម្រេចក្នុងខណៈដែលមានការផ្តន្ទាទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងនោះ។

២. យើងខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ ដែលអ.វ.ត.ក បានបើកទ្វារដល់ដើមបណ្តឹងរដ្ឋប្បវេណី ជាលើកដំបូងនៅក្នុងតុលាការអន្តរជាតិ ហើយជាការពិត ការអនុញ្ញាតបែបនេះនឹងធ្វើឲ្យនីតិវិធីមានលក្ខណៈពិសេស ហើយពោរពេញទៅដោយឧបសគ្គបន្ថែម ភាពមិនច្បាស់លាស់បន្ថែម ហើយនិងការជជែកដេញដោលគ្នាបន្ថែមទៅទៀត។ ទោះបីជាតាមព្រឹត្តន័យវាធ្វើឲ្យដំណើរការជំនុំជម្រះ កាន់តែមានរយៈពេលយូរក៏ដោយ ក៏ការជំនុំជម្រះក្តីទៅលើអ្នកដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យអាចបញ្ជាក់ពីវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន។ ជាការពិត តើយើងអាចកាត់សេចក្តីចំពោះអ្វី ដែលបានប៉ះពាល់ដល់គ្រួសារនីមួយៗ ភូមិនីមួយៗនៃប្រទេសកម្ពុជា ដែលបន្សល់ទុកនៅស្លាកស្នាមយ៉ាងច្បាស់ក្នុងរយៈពេល៣០ឆ្នាំក្រោយមកដោយគ្មានវត្តមានរបស់ជនរងគ្រោះយ៉ាងម៉េចនឹងកើត? តើអ្នកណា នឹងអាចរៀបរាប់អំពីរឿងរ៉ាវដ៏ឃោរឃៅដែលបានកើតឡើង ហើយស្នើសុំឲ្យលាតត្រដាងការពិត ហើយផ្តល់យុត្តិធម៌តាមផ្លូវច្បាប់បានប្រសើរជាងជនរងគ្រោះទាំងនោះៗ? អ្វីដែលជាទម្ងន់នៃអង្គហេតុដែលបានចោទប្រកាន់ និងអ្វីដែលធ្វើឲ្យអង្គហេតុចោទប្រកាន់ក្លាយទៅជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋ

កម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺថាអំពើទាំងអស់ នេះត្រូវបានប្រព្រឹត្តទៅលើបុគ្គលដែលមកស្នើសុំឲ្យផ្តល់យុត្តិធម៌ ទោះបីជាដោយប្រយោល ឬដោយ ផ្ទាល់ក្តី។ បើគ្មានជនរងគ្រោះទេ នោះមិនមានបទឧក្រិដ្ឋទាំងនោះទេ។

៣. អង្គជំនុំជម្រះចង់បានសេចក្តីបញ្ជាក់ឲ្យកាន់តែច្បាស់អំពីសំណង យើងខ្ញុំមានសេចក្តីសប្បាយរីករាយអំពីការទាមទារនេះ ពីព្រោះយើងខ្ញុំយល់ថា នេះគឺជាកាយវិការមួយដែលបង្ហាញថា អង្គជំនុំជម្រះកំពុងតែយកចិត្តទុកដាក់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណងដែលត្រូវផ្តល់ដោយជនជាប់ចោទពេលដែលពិរុទ្ធភាពត្រូវបានលាតត្រដាង។ អាស្រ័យទៅតាមពេលវេលាដែលបានផ្តល់ជូន យើងខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះនូវរាល់សេចក្តីបញ្ជាក់ចាំបាច់ទាំងអស់ យើងខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះនូវការបញ្ជាក់ចាំបាច់នានា៖ ដំបូងគឺពាក់ព័ន្ធទៅនឹងស្ថានភាពនៃដំណើរការបង្កើត ព្រមទាំងការសហការរបស់យើងខ្ញុំជាមួយនឹងអ្នកដែលធ្វើការជាមួយយើងខ្ញុំ ជាពិសេសគឺអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ យើងខ្ញុំនឹងបង្ហាញជូននូវបញ្ហាចោទរបស់យើង ជាពិសេសយោងទៅលើបរិបទច្បាប់ និងនីតិវិធីដែលលោកប្រធានបាននិយាយកាលពីអម្សាញ់មិញនេះ ហើយគឺពាក់ព័ន្ធនឹងបរិបទផ្ទៃក្នុង និងខាងក្រៅ អ.វ.ត.ក ហើយយើងនឹងផ្តល់សេចក្តីបញ្ជាក់ និងព័ត៌មានបន្ថែមទៅតាមការទាមទាររបស់អង្គជំនុំជម្រះ ហើយយើងខ្ញុំក៏នឹងបង្ហាញជូនអំពីការពិចារណាផ្ទាល់ខ្លួនផងដែរ តាមរបៀបផ្សេងៗនៅក្នុងបរិបទច្បាប់ និងនីតិវិធីដែលនឹងចូលរួមចំណែកដល់ការតាក់តែងសំណងទាំងអស់នេះ។ ក្នុងខណៈនេះ យើងនឹងលើកឡើងបន្តទៀតនូវការឆ្លើយតបរបស់យើងទៅនឹងការកត់សម្គាល់របស់អង្គជំនុំជម្រះដែលបានបង្ហាញជូននៅក្នុងអនុស្សរណៈលេខ E125។ បន្ទាប់យើងខ្ញុំនឹងលើកឡើងអំពីការបញ្ជាក់បន្ថែម និងខ្លឹមសារបឋមដែលជាក្របខ័ណ្ឌច្បាប់នៃសំណងទាំងអស់នេះ ដោយមិននិយាយដដែលៗជាមួយនឹងអ្វីដែលបាននិយាយរួចមកហើយនៅក្នុងសវនាការបឋមនោះ។ យើងនឹងងាកមកនិយាយអំពីគម្រោងនីមួយៗ ដើម្បីផ្តល់នូវសេចក្តីពន្យល់បំភ្លឺ និងព័ត៌មានលម្អិតបន្ថែមទៅទៀត។

យើងខ្ញុំសូមបញ្ជាក់ផងដែរថា សំណងទាំងអស់នេះ គឺកើតចេញពីការងារសមូហភាព ហើយមិនមែនការងារដែលធ្វើដោយអត្តនោម័តនោះទេ គឺយើងធ្វើដើម្បីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

## II. **ដំណើរការនៃការតាក់តែងសំណើស្នើសុំសំណង**

### **ក. ដំណើរការតាក់តែងសំណើ**

៤. ជាដំបូងយើងខ្ញុំសូមបញ្ជាក់ជូនអំពីច្បាប់ និងសេចក្តីប៉ងប្រាថ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី ថាតើបានដំណើរការដល់ណាហើយនោះ។ ចាប់ពីពេលមានដីកាស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសទទួលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅក្នុងសំណុំរឿង ០០២ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអង្គភាពគាំពារជនរងគ្រោះ និងអង្គការដៃគូរ បានដំណើរការពិគ្រោះយោបល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២១២២នាក់ ដែលរស់នៅកម្ពុជា និងនៅបរទេស។ ហើយបន្ទាប់ពីបានទទួលនូវលទ្ធផលនៃការពិគ្រោះយោបល់នេះ សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដោយសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ហើយនិងអង្គការក្រៅរដ្ឋាភិបាល បានធ្វើការវិភាគយ៉ាងពេញលេញ ហើយនិងការសំយោគទៅលើទិន្នន័យទាំងអស់ដើម្បីកម្រិតនូវដែនកំណត់ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចង់ទទួលបាន។

៥. ហើយយោងទៅតាមវិធាន២៣ថ្មីក្នុង យើងមានកាតព្វកិច្ចក្នុងការផ្តល់នូវសេចក្តីបញ្ជាក់បន្ថែមអំពីខ្លឹមសារនៃសំណងដែលនឹងត្រូវស្នើសុំ ហើយយើងនឹងនិយាយអំពីបំណងរួមរបស់យើង ដើម្បីធ្វើជាគម្រោងមួយដែលមានលក្ខណៈរលូន ស៊ីសង្វាក់គ្នា ហើយដែលអាចប្រព្រឹត្តទៅបាន។ ធាតុដ៏សំខាន់នៅក្នុងដំណើរការនេះ គឺថាយើងត្រូវតែបញ្ជាក់នៅក្នុងសំណុំរឿង០០២ ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ចង់បាននូវអ្វីជាសំណងដែលមានបង្ហាញនៅក្នុងសំណុំរឿង០០១ ប៉ុន្តែដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះ សាលាដំបូងនៅក្នុងសាលក្រម ចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ បានធ្វើបណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូលទៅលើបញ្ហាសំណង ហើយ

អង្គជំនុំជម្រះត្រូវតែសម្រេចទៅលើបញ្ហានេះ។ ដូច្នេះយើងខ្ញុំត្រូវបានបង្ខំឲ្យមានប្រតិកម្មបន្តិច ឬក៏គ្មានលើចំណុចច្បាប់នៅត្រង់នេះ។ ទោះបីជាមានឧបសគ្គបែបនេះក៏ដោយ កាលពីខែមិថុនា ឆ្នាំ២០១១ យើងបានកំណត់នូវសំណើបួនប្រភេទ ហើយនៅក្នុងនោះមានសំណើតូចៗជាច្រើន។ នៅថ្ងៃទី២៤ មិថុនា ឆ្នាំ២០១១ គឺប្រាំថ្ងៃមុនថ្ងៃដែលសហមេធាវីនាំមុខត្រូវផ្តល់សេចក្តីបញ្ជាក់បឋម អ្នកដាក់ពាក្យសំណុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧៥០នាក់ ដែលសហចៅក្រមស៊ើបអង្កេតបានបដិសេធកន្លងមក ត្រូវបានសម្រេចទទួលស្គាល់ បន្ទាប់ពីដាក់បណ្តឹងសារទុក្ខ។ ចំនុចចុងក្រោយនេះ បានធ្វើឲ្យយើងខ្ញុំមានការពេញចិត្តយ៉ាងខ្លាំង ប៉ុន្តែវាមានផលប៉ះពាល់យ៉ាងច្បាស់លាស់ទៅលើតម្លៃនៃការចង្អុលបញ្ជាក់បឋមនៃសំណងដែលយើងបានរកឃើញ ហើយវាគឺតំណាងឲ្យពាក់កណ្តាលនៃការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

៦. យោងតាមវិធាន៨០ស្ទួន នៅថ្ងៃទី២៩ មិថុនា សហមេធាវីនាំមុខ បានដាក់ជូនដោយផ្ទាល់មាត់នូវខ្លឹមសារបឋមពាក់ព័ន្ធទៅនឹងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយនៅពេលនោះ ក៏យើងបានលើកឡើងអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្តី ពីព្រោះថា ពួកគាត់មានសិទ្ធិក្នុងការទាមទារសំណង ហើយយើងក៏បានបង្ហាញអំពីសំណើសុំសំណងដែលយើងនឹងចាត់ទុកថាវាគឺជាការចង្អុលបង្ហាញខ្លឹមសារបឋម។

## ខ. អំពីការសហការជាមួយនឹងសង្គមស៊ីវិល

៧. ហើយយើងបានកំពុងតែធ្វើការបង្កើតគម្រោងនេះជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលដើម្បីឲ្យយើងទទួលបន្ទុកទៅលើការសម្រេចគម្រោងទាំងអស់នេះពាក់ព័ន្ធទៅនឹងភាពអាចសម្រេចបាន ហើយនិងនិរន្តរភាព។ហើយការបញ្ជាក់ជូននេះ គឺថាអាចធ្វើឲ្យអង្គជំនុំជម្រះឃើញថា ការបង្កើតសំណងគឺវាមិនមែនជារឿងអរូបីនោះទេ គឺវាជាការដ្ឋានមួយដែលយើងកំពុងតែធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

## III. បរិបទនីតិវិធីបច្ចុប្បន្ន និងឧបសគ្គដែលជាប់ពាក់ព័ន្ធ

### ក. អំពីវិធាន ៨០ ស្ទួន

៨. វិធាន៨០ស្ទួន ដែលនិយាយអំពីសវនាការបឋមបាននិយាយថា អង្គជំនុំជម្រះ៖“អាចបង្គាប់ឲ្យសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញជាលក្ខណៈបឋមនូវខ្លឹមសារជាក់លាក់នៃសំណើសុំសមូហភាព ហើយនិងផ្លូវចិត្តដែលខ្លួនចង់ទាមទារនៅក្នុងសំណើសុំចុងក្រោយ។ យើងមិននិយាយចំណាយពេលច្រើនទៅលើវិធីដែលយើងត្រូវធ្វើនោះទេ ហើយពាក់ព័ន្ធទៅនឹងការបកស្រាយដែលសហមេធាវីនាំមុខ និងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅវិធាន៨០ស្ទួន។ យើងគិតថាយើងបានធ្វើការវាយតម្លៃសមស្រប ហើយនិងមានភាពរឹងមាំខាងផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងវិធានកាតព្វកិច្ចទាំងអស់នេះយោងទៅតាមវិធាននេះ ហើយក៏វាមិនមានការចាំបាច់អីទេក្នុងការយើងផ្តល់នូវការបកស្រាយដែលមានលក្ខណៈផ្សេងៗជាច្រើននោះ។

៩. ហេតុដូច្នេះ ការជជែកដេញដោលនៅក្នុងច្បាប់ គឺថាគឺធ្វើឲ្យមានការមិនយល់ មិនមានការឯកភាពគ្នារវាងភាគី ហើយនិងតុលាការលើអំណាន និងអត្ថន័យច្បាប់។ ដូច្នេះខ្ញុំសូមឲ្យខ្ញុំបញ្ជាក់អំពីការមិនយល់ឯកភាពគ្នានេះ។ យើងគិតថាវិធាន៨០ស្ទួន គឺថានៅក្នុងដំណាក់កាលនៃនីតិវិធីនេះ មិនតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវព័ត៌មានលម្អិតស្តីអំពីសំណើសុំសំណងដែលកំពុងតែតាក់តែង ហើយនិងក៏មិនតម្រូវឲ្យមានការនិយាយអំពីវិធីនៃការអនុវត្តសំណងទាំងអស់នេះដែរ ។ដូច្នេះនៅក្នុងដំណាក់កាលនេះ យោងទៅតាមឯកសារលេខE86 និងឯកសារE86/1 គឺគេតម្រូវឲ្យយើងគ្រាន់តែបង្ហាញអំពីខ្លឹមសារបឋមតែប៉ុណ្ណោះនៃសំណង។ ក៏ប៉ុន្តែយើងចាត់ទុកថា សវនាការនៅថ្ងៃនេះ គឺជាឱកាសមួយដ៏មានតម្លៃសម្រាប់ផ្តល់ជូនទៅនឹងតុលាការស្តីអំពីបច្ចុប្បន្នភាពនៃការដំណើរការសំណងរបស់យើងខ្ញុំ។ យើងគិតថា វាក៏ជាចំណុចចាប់ផ្តើមនៃការសន្ទនាគ្នាជាអចិន្រ្តៃយ៍ជាមួយតុលាការទៅលើបញ្ហាជាក់លាក់ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ និងការសម្រេចបាននូវសំណើសុំចុងក្រោយនេះ។

១០. នៅកថាខណ្ឌទី៨ នៃអនុស្សរណៈ E125 ដែលចុះថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានបញ្ជាក់ថាគោលបំណងនៃការបង្ហាញពីខ្លឹមសារបឋមនេះ គឺអាចធ្វើឲ្យសំណងនេះមានលក្ខណៈច្បាស់លាស់ជាងមុន ហើយនិងមានការគ្រោងទុកជាមុន ដើម្បីជាផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីរួម ហើយនិងផ្តល់ទៅឲ្យអង្គជំនុំជម្រះនូវដំណាក់កាលមុនមួយឲ្យបានជាក់លាក់តាមដែលអាចធ្វើទៅបាន[1]។ ដូច្នេះយើងខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីផ្តល់នូវការធានាជូនអង្គជំនុំជម្រះថា សហមេធាវីនាំមុខ ហើយនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺកំពុងតែមានការព្រួយបារម្ភនៅក្នុងការតាក់តែង ឬបង្កើតនូវសំណើសុំសំណងដែលមានលក្ខណៈរឹងមាំតាមផ្លូវច្បាប់ ហើយនិងមានផែនការច្បាស់លាស់។

១១. ដូច្នេះអាណត្តិរបស់យើង គឺត្រូវតែធ្វើការស្នើសុំសំណងជាសមូហភាព និងតាមផ្លូវចិត្ត តាំងនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីយោងទៅតាមវិធាន២៣ នៃវិធានផ្ទៃក្នុង[2]។ ដូច្នេះយើងខ្ញុំសូមបញ្ជាក់ម្តងជាថ្មីទៀតថាការកំណត់ ហើយនិងការបង្កើតនូវសំណងទាំងអស់នេះ គឺវាជាតួនាទីរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការជួយជ្រោមជ្រែងពីអង្គភាពផ្សេងៗដែលខ្លួនធ្វើការជាមួយ ដូចជាអង្គភាពគាំពារជនរងគ្រោះ អង្គការក្រៅរដ្ឋាភិបាល ហើយនិងការជំនួយពីរដ្ឋាភិបាលផងដែរ។

១២. លើសពីនេះ ដូច្នេះយើងសូមឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់អង្គជំនុំជម្រះនៅក្នុងអនុស្សរណៈ E125 ចុះថ្ងៃទី២៣ កញ្ញា ដែលក្នុងនោះ គឺបានបញ្ជាក់ថា វិធានការដែលបានស្នើសុំដំបូងនោះ គឺមិនមានភាពគ្រប់គ្រាន់នោះទេ ហើយគឺថាវាមិនមាន លក្ខណៈឲ្យមានខ្លឹមសារគ្រប់គ្រាន់ទេនៅក្នុងដំណាក់កាលនេះ។ ដូច្នេះសហមេធាវីនាំមុខហើយនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថាវិធាន៨០ស្ទួននៃវិធានផ្ទៃក្នុង គឺតម្រូវឲ្យខ្លួនបញ្ជាក់តែជាបឋមអំពីខ្លឹមសារនៃសំណងនោះតែប៉ុណ្ណោះ ហើយក្នុងវិធាននេះទៀត ហាក់ដូចជាមិនបានបញ្ជាក់ថា អង្គជំនុំជម្រះ គឺមិនអាចមានធ្វើអន្តរាគមន៍

[1] អនុស្សរណៈ E125 ដែលចុះថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១១ ទំព័រ ៣ ។

[2] វិធានផ្ទៃក្នុង (កំណែប្រែលើកទី ៨) ។

ទៅក្នុងការធ្វើផែនការ ឬក៏អាចបង្ហាញនូវសេចក្តីសម្រេច ឬក៏មានការសង្កេតអ្វីមួយទៅលើលក្ខណៈនេះដែរ។

១៣. ដូច្នេះ យើងសូមបញ្ជាក់បន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីដាច់ដោយឡែក និងមានឯករាជ្យនៅក្នុងការដំណើរការក្តីនៅចំពោះមុខ អ.វ.ត.ក ។ ទោះបីជាយើងយល់ថា ការរៀបចំផែនការជាមុននោះមានលក្ខណៈសំខាន់ក៏ដោយ ហើយទោះបីជាយើងដឹងថា សំណាងនេះ គឺត្រូវតែធ្វើឡើងនៅមុនពេលធ្វើសវនាការនេះក៏ដោយ ក៏យើងដឹងថា ក៏យើងផ្តល់សារៈនសំខាន់ទៅលើបញ្ហាច្បាប់ និងអាចអនុវត្តបានដែលអាចប៉ះពាល់ទៅដល់ការអភិវឌ្ឍន៍សំណាង ដូចដែលបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណី។ ហើយនៅដំណាក់កាលនេះ នៅពេលដែលដំណើរការមិនទាន់បាននិយាយអំពីការប្រកាសពីពិរុទ្ធភាព ឬភាពគ្មានទោសនោះ គឺយើងវាពិបាកណាស់ក្នុងការពិភាក្សាឲ្យលម្អិតអំពីផែនការ ដែលត្រូវពាក់ព័ន្ធទៅនឹងគម្រោងទាំងអស់នេះ។

## ខ. អំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០១ កំពង់ដំណើរការ

១៤. គួរកត់សម្គាល់ថា យើងមានការធ្វើបណ្តឹងសាទុក្ខ ហើយកំពុងតែនៅក្នុងចំណាត់ការរបស់អង្គជំនុំជម្រះតុលាការកំពូល ទោះបីជាមានការផ្លាស់ប្តូរទៅលើវិធានផ្ទៃក្នុង ដែលមានការផ្លាស់ប្តូរទៅលើវិធានសំខាន់មួយចំនួននៅក្នុងសំណុំរឿង០០១ ក៏ដោយក៏ចំណុចអង្គច្បាប់មួយចំនួនក៏នៅដដែល ហើយក៏មិនមានការប៉ះពាល់ដល់ការផ្លាស់ប្តូរនេះដែរ ហើយក៏វាអាចមិនមានការពាក់ព័ន្ធទៅនឹងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលដែរ។ វិធានច្បាប់ គឺចង់ឲ្យភាគីទាំងអស់ជជែកតវ៉ា ហើយនិងរិះគន់ទៅលើសេចក្តីសម្រេច ដែលបង្កើតបានជាច្បាប់ជាមូលដ្ឋានមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់អត់អាចប្រើប្រាស់បាន ហើយយើងនឹងបង្ហាញអំពីការមិនព្រមព្រៀងរបស់យើង។

១៥. ការលំបាកទីមួយ គឺថានៅសំណុំរឿងដែល០០១ នោះ ដែលមានពាក់ព័ន្ធនឹងសំណាងនោះ អង្គជំនុំជម្រះមិនបានបង្ហាញអំពីសំអាងហេតុ ឬក៏មូលដ្ឋានគតិយុត្តនោះទេ ហើយដោយគ្មានការបង្ហាញបែបនេះ

ដើមបណ្តឹងរដ្ឋប្បវេណី គឺថាគាត់ពិបាកក្នុងការធ្វើសម្មតិកម្មពាក់ព័ន្ធទៅនឹងការវិភាគដល់អង្គជំនុំជម្រះអាចធ្វើបានទៅលើសំណងទាំងអស់នេះ។ ដូច្នេះវាមានអត្ថទោសទៅដល់មេធាវីនៅក្នុងបេសកកម្មរបស់ខ្លួននៅក្នុងការការពារផលប្រយោជន៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏វាផ្ទុយទៅនឹងបទប្បញ្ញត្តិមួយចំនួននៃច្បាប់អន្តរជាតិ និងវិធានផ្ទៃក្នុងដោយធានានូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវសំណង។

១៦. ដូច្នេះយើងខ្ញុំសូមបញ្ជាក់ជាបន្តទៀតជូនអង្គជំនុំជម្រះថា អង្គជំនុំជម្រះហាក់ដូចជាមានការបកស្រាយមួយដែលមានលក្ខណៈចង្អៀតទៅលើសញ្ញាណនៃសំណងសមូហភាព និងផ្លូវចិត្ត ហើយអ្វីដែលនេះអ្វីទាំងអស់នេះ គឺយើងគិតថា វាមានលក្ខណៈបុគ្គល ហើយនិងហិរញ្ញវត្ថុ។ ជាថ្មីម្តងទៀត យើងប្រើពាក្យហាក់ដូចជានេះ ពីព្រោះថា អង្គជំនុំជម្រះ គឺថាមិនបានបង្ហាញនូវសំអាងហេតុជាក់លាក់នោះទេនៅក្នុងសាលក្រមរបស់ខ្លួននោះ។

១៧. ច្បាស់ជាងនេះទៀត ហើយបញ្ហាពាក់ព័ន្ធទៅនឹងការបង្កើតមូលនិធិស្ម័គ្រចិត្ត ហើយនិងវិធាននៅក្នុងសំណងដែលទាមទារឲ្យមានការឯកភាពពីរដ្ឋាភិបាលនោះ គឺថាទាមទារឲ្យមានការយល់ព្រមពីរដ្ឋាភិបាល ហើយកំពុងតែត្រូវបានមានចំណាត់ការនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ហើយនៅលើចំណុចនេះ មេធាវីក៏បានបង្ហាញថា នៅក្នុងសំណុំរឿង០០១ នេះអង្គជំនុំជម្រះ គឺថាមិនបានដោះស្រាយទៅលើបញ្ហាបង្កើតមានមូលនិធិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយមេធាវីដើមបណ្តឹងរដ្ឋប្ប-វេណី ដូច្នេះចង់ឲ្យតុលាការកំពូល គឺប្រកាសសាលដីកាទៅលើការទាមទារនេះ។

១៨. ទៅលើបញ្ហាទីពីរ គឺពាក់ព័ន្ធទៅនឹងវិធានការដែលតម្រូវឲ្យមានការឯកភាពពីរដ្ឋាភិបាលកម្ពុជា គឺថាចំណុចនេះត្រូវបានបដិសេធទៅដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ឌុច ហើយដែលគាត់ចាត់ទុកថា វាខុស វាក្រៅពីយុត្តាធិការរបស់ អ.វ.ត.ក។ ហើយជាថ្មីម្តងទៀត មេធាវីបានធ្វើបណ្តឹងសាទុក្ខដែលបញ្ជាក់ថា ប្រសិនបើតុលាការមិនមានយុត្តាធិការក្នុងការបង្គាប់ឲ្យមានសំណងទៅលើ

រដ្ឋាភិបាលកម្ពុជានោះទេ គឺខ្លួនអាចបង្គាប់ឲ្យជនជាប់ចោទមានវិធានការពាក់ព័ន្ធនឹងសំណងនេះ ហើយអាចទាមទារឲ្យមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាល ហើយម្យ៉ាងវិញទៀតមេធាវីសូមរំឭកថា សិទ្ធិក្នុងការទទួលសំណងនេះគឺថាមានចែងនៅ --មានទទួលស្គាល់នៅច្បាប់អន្តរជាតិ[3] ហើយព្រះរាជណាចក្រកម្ពុជា គឺថាគាត់មានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការផ្តល់នូវសំណងទៅដល់ជនរងដែលទទួលរងនៅក្នុងរបបខ្មែរក្រហម។

១៩. អង្គជំនុំជម្រះតុលាការកំពូលគឺកំពុងតែចាត់វិធានការទៅលើបញ្ហាទាំងអស់នេះ ដើម្បីឲ្យមានលក្ខណៈច្បាស់លាស់ ហើយវាគឺជាបញ្ហាមួយទៀតដែលមានលក្ខណៈសំខាន់ណាស់សម្រាប់សហ-មេធាវីនាំមុខ ហើយនិងមេធាវីម្នាក់នោះដែលកំពុងតែបង្កើត ហើយនិងបញ្ជាក់នូវសំណង សំណើសុំសំណងនៅក្នុងសំណុំរឿង០០២ បន្ទាប់ពីសំណុំរឿង ឌុច។

២០. ហើយនៅក្នុងបណ្តឹងសាទុក្ខនោះ គឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះមិនបានប្រាប់ជូនទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី នូវលក្ខណៈវិនិច្ឆ័យនៃការទទួលយកសំណើដើម្បី

---

[3] សូមមើល គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានការជួសជុល និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ UN General Assembly resolution 60/147 ។ សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស។ កិតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ មាត្រា ២ (៣), មាត្រា ៩ (៥) និង មាត្រា ១៤ (៦)។ សន្ធិសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៦។ សន្ធិសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣៩។ សន្ធិសញ្ញាប្រឆាំងនឹងការធ្វើទណ្ឌកម្ម មាត្រា ១៤។ សន្ធិសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលដែលបាត់ខ្លួនដោយបង្ខំ មាត្រា២៤។ កិត្តិការសញ្ញាទីក្រុងរ៉ូម មាត្រា៧៥ ។ សូមមើផងដែរ លិខិតូបករណ៍ក្នុងតំបន់ដូចជា សន្ធិសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា៥(៥)។ សន្ធិសញ្ញាអាមេរិចកាំងស្តីពី សិទ្ធិមនុស្ស មាត្រា២៥ មាត្រា៦៣ (១) និង មាត្រា៦៨។ ធម្មនុញ្ញអាហ្វ្រិចស្តីពី សិទ្ធិមនុស្ស មាត្រា២១ (២)។ ហើយសូមមើលផងដែរ យុត្តសាស្ត្រអន្តរជាតិដូចជា គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអត្ថាធិប្បាយទូទៅ លេខ ៣១ វាក្យខ័ណ្ឌ ១៥ ដល់ ១៧។ គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងនឹង ការធ្វើទារុណកម្ម សេចក្តីអត្ថាធិប្បាយទូទៅ លេខ ២ វាក្យខ័ណ្ឌ ១៥។តុលាការសិទ្ធិមនុស្សអន្តរអាមេរិចកាំង រឿងក្តី *Velasquez-Rodriguez v Honduras,* វាក្យខ័ណ្ឌទី ១៧៤។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប រឿងក្តី *Paamichalopou v. Greece* វាក្យខ័ណ្ឌ ៣៦។

ទទួលបានសំណងនេះទេ។ ហើយចាប់ពីពេលដែលទទួលបាននូវការទាមទារបែបនេះ គឺថាវាគ្មានមូលដ្ឋានច្បាប់នោះទេ នៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ហើយទោះបីជាថាកម្រិតនៃភាពជាក់លាក់នៅតែជាបញ្ហាមួយដែលបើកចំហ ដែលតាមរយៈនោះគឺអង្គជំនុំជម្រះតុលាការកំពូលអាចនឹងផ្តល់នូវធាតុផ្សំមួយដែលមានលក្ខណៈសំខាន់។ ហើយនៅពេលដែលយើងអនុវត្តស្តង់ដារខ្ពស់ពេកនៅក្នុងសំណុំរឿង០០១ នោះគឺអង្គជំនុំជម្រះរំលោភទៅលើសិទ្ធិទទួលបានសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ យើងខ្ញុំសូមស្នើឱ្យតុលាការដកស្រង់នូវការអនុវត្តនៃតុលាការអន្តរជាតិផ្សេងទៀតទាំងនៅក្នុងតំបន់ និងអន្តរជាតិទាក់ទងទៅនឹងបញ្ហាសំណងនេះ។ ឧទាហរណ៍ ដូចជារបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ហើយនិងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

២១. ដូច្នេះយើងខ្ញុំកំពុងតែរង់ចាំនូវសាលាដីការបស់តុលាការកំពូលទៅលើបញ្ហានេះ ហើយយើងសង្ឃឹមថាសេចក្តីបញ្ជាក់ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងចេញនោះគឺថា នឹងជាការវិភាគទានមួយយ៉ាងសំខាន់ទៅដល់ការងារបង្កើតសំណង ហើយនិងការធ្វើឱ្យសំណងនោះមានភាពលក្ខណៈជាក់លាក់ល្អនោះ។ ហើយបន្ថែមទៅលើទឡ្ហីករណ៍ដែលបានបញ្ជាក់ជូននៅក្នុងនេះ គឺថាវាមានមូលហេតុបន្ថែមមួយទៀត ដោយសារគិតថា គឺវាមិនមានលក្ខណៈសមស្របនោះទេនៅក្នុងដំណាក់កាលនេះដែលទាមទារឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញជាស្ថាពរទៅលើសំណង សំណើសុំសំណង ហើយនិងពីគំនូសបំព្រួញ ឬក៏ផែនការជាក់លាក់នៃសំណងទាំងអស់នេះ។ ដូច្នេះយើងកំពុងតែរង់ចាំនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដើម្បីឱ្យមានព័ត៌មានជាក់លាក់ថា តើយើងត្រូវធ្វើបែបណានៅក្នុង--ពាក់ព័ន្ធទៅនឹងសំណងរបស់យើងនេះ។

## គ. អំពីដីកាបំបែកកិច្ចដំណើរការនីតិវិធី

២២. ដូច្នេះពេលនេះយើងខ្ញុំនឹងនិយាយអំពីផលវិបាកទៅលើដើមបណ្តឹងរដ្ឋប្បវេណីអំពីដីកាដែលបានបំបែកកិច្ចនីតិវិធី។ អង្គជំនុំជម្រះសាលាដំបូងបានចេញកាលពីថ្ងៃទី២២ កញ្ញា នូវដីកាមួយពាក់ព័ន្ធនឹងការ

បំបែកនីតិវិធីដោយយោងតាមវិធាន ៨៩ស្ទួន(២) នៃវិធានផ្ទៃក្នុង ដែលក្នុងនោះអង្គជំនុំជម្រះបាននិយាយថា បំបែកបទចោទនៅក្នុងសំណុំរឿង០០២ ហើយនិងបែងចែកទៅជាសំណុំតូចៗ ហើយនៅក្នុងសំណុំរឿងទាំងអស់នោះគឺថា វាកាបែងចែកគ្នារវាងបទចោទ ហើយនិងមានបញ្ហាគតិយុត្តផ្សេងៗគ្នា[4]។

២៣. ដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា ដំណាក់កាលជំនុំជម្រះដំបូងនៅក្នុងសំណុំរឿង០០១ នោះគឺនិយាយតែពីលើការចោទប្រកាន់ពីអង្គហេតុ ដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំប្រជាជននៅក្នុងដំណាក់កាលទីមួយ ទីពីរ ហើយនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយលើកលែងទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា។ នៅពេលធ្វើបែនេះគឺអង្គជំនុំជម្រះបានដកចេញនូវសហករណ៍ការដ្ឋានការងារ មន្ទីរសន្តិសុខ ហើយនិងមន្ទីរពិឃាត ហើយនិងអង្គហេតុទាំងនោះពាក់ព័ន្ធទៅនឹងការជម្លៀសទៅនឹងដំណាក់កាលទីបី។ ហើយអង្គជំនុំជម្រះក៏ដកចេញនូវបទចោទពាក់ព័ន្ធទៅនឹងប្រល័យពូជសាសន៍ ហើយនិងការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ផ្ទុយទៅវិញ អង្គជំនុំជម្រះក៏បានបញ្ជាក់ថាខ្លួនរក្សាសិទ្ធិក្នុងការបញ្ចូលគ្រប់ពេលទាំងអស់នូវការពិនិត្យនូវបទចោទផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះដំបូងនេះ ក្នុងលក្ខខណ្ឌដែលថាត្រូវតែគោរពសិទ្ធិក្នុងការការពារខ្លួន។

២៤. សហព្រះរាជអាជ្ញាបានដាក់នូវសំណើមួយដើម្បីឲ្យពិនិត្យឡើងវិញ[5]ទៅលើដីកាបំបែកនីតិវិធីនេះនៅថ្ងៃទី១៤ តុលា ហើយសំណើនេះគឺថាបើតាមអ្នកច្បាប់របស់អង្គជំនុំជម្រះចុះថ្ងៃទី១៤ តុលា នោះបាននិយាយថា ថ្ងៃទី១៨ តុលា ដើមបណ្តឹងរដ្ឋប្បវេណីគឺបានជូនដំណឹងអំពីការស្នើសុំឲ្យមានការពិនិត្យឡើង

---

[4] អនុស្សរណៈនៃអង្គជំនុំជម្រះសាលាដំបូង ដីកាបំបែកកិច្ចដំណើការនីតិវិធីដោយអនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង ឯកសារលេខ E124។

[5] សូមមើល សំណើសុំពិនិត្យឡើងវិញរបស់សហព្រះរាជអាជ្ញាលើដីកាបំបែកកិច្ចដំណើការនីតិវិធីដោយយោងតាមវិធាន ៨៩ ស្ទួននៃវិធានផ្ទៃក្នុង ឯកសារលេខ E124/2។

វិញ ហើយដែលមានការគាំទ្រដោយផ្អែកទៅលើសំណើរបស់សហព្រះរាជអាជ្ញា។ ហើយ ។ នៅល្ងាច ថ្ងៃទី១៨ តុលា អង្គជំនុំជម្រះមានចេញសេចក្តីសម្រេចបដិសេធសំណើយើងខ្ញុំដោយមិនបានពិនិត្យលើសារណារបស់យើងខ្ញុំ។

២៥. ដើមបណ្តឹងរដ្ឋប្បវេណីព្រួយបារម្ភថា បើតាមតុលាការគឺថា ការបំបែកនីតិវិធីនេះ កម្រិតនូវការពិនិត្យទៅលើអង្គហេតុហើយដែលជាកម្មវត្ថុនៃការជំនុំជម្រះដំបូងនោះ ហើយវាអត់មានផលបះពាល់អីទៅលើខ្លឹមសារនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងដំណាក់កាលនេះទេ ហើយវាក៏មិនមានពាក់ព័ន្ធអីទៅលើរបៀបដែលដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំសំណងតាំងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ។

២៦. នៅក្នុងការបដិសេធចំពោះសំណើសុំលើកពេលសវនាការនេះ អង្គជំនុំជម្រះបានទទួលស្គាល់ថាដីកាបំបែកនីតិវិធីនេះ គឺថាអាចមានផលប៉ះពាល់ទៅលើសំណង។ ដូច្នេះ យើងបាននិយាយថា ផលប៉ះពាល់នេះ វាមិនមែនជាលទ្ធភាពនោះ គឺវាច្បាស់លាស់តែម្តង។

២៧. វិធាន២៣ ស្ទួន៤(២) ចំណុច ខ ចង់ឲ្យសារណាដែលបង្ហាញអំពីសំណើសំណងនោះ បញ្ជាក់ថា អ្វីទៅជាសំណងដែលចង់ទាមទារទាំងនេះឆ្លើយតបនឹងព្យសនកម្មដែលទទួលរង និងបញ្ជាក់ក្នុងករណីអាចធ្វើទៅបាន ពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមរួមដែលទទួលរងព្យសនកម្មនោះ។ ផ្ទុយទៅវិញ វិធាននេះមិនបានអនុវត្តទេ ដោយសារអង្គជំនុំជំម្រះបានពិចារណាក្នុងសាលក្រមក្នុងសំណុំរឿង០០១ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញនូវភស្តុតាងជូនអង្គជំនុំជំម្រះលើអត្ថិភាពនៃកំហុសរបស់ជនជាប់ចោទ និងចំណងហេតុផលផ្តល់រវាងកំហុស និងព្យសនកម្មដែលទទួលរងជាលក្ខណៈបុគ្គល[6] ហើយនឹងត្រូវបង្ហាញឲ្យច្បាស់នូវប្រភេទវិធានការដែលស្នើសុំ និងបង្ហាញអ្វីជាចំណងរវាងកំហុស និងព្យសនកម្មដែលបង្កដោយជនជាប់ចោទ និងវិធានការដើម្បីជួសជុលសំណង និងចុងបញ្ចប់បង្ហាញ

[6] សាលក្រមក្នុងសំណុំរឿង០០១ វាក្យខ័ណ្ឌ ៦៣៩។

ចំនួនសោហ៊ុយត្រូវសងដែលស្នើសុំទៅជនជាប់ចោទដើម្បីឲ្យមានប្រសិទ្ធិភាព[7]។អង្គជំនុំជំម្រះបានបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជំម្រះមិនអាចផ្ដើមសម្រេចលើបញ្ហាបែបទាំងនេះទេ[8]។

២៨. ហេតុដូចនេះ នៅពេលស្នើសុំសំណងរដ្ឋប្បវេណី មេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញពីចំណងចាំបាច់រវាងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានរឃើញថាមានពិរុទ្ធភាព និងព្យសនកម្ម ព្រមទាំងរវាង ព្យសនកម្ម និងវិធានការស្នើសុំក្នុងគោលដៅជួសជុលសំណងមុនពេលដោះស្រាយបញ្ហានៃការអនុវត្តគម្រោង និងសម្ភារៈផ្សេងៗ ។ ចំណុចនេះ វាមិនអាចទៅរួចទេ នៅពេលដែលបទល្មើស ឬដើមបណ្ដឹងរដ្ឋប្បវេណីមិនទាន់ត្រូវបានកំណត់ឲ្យបានជាក់លាក់នោះទេ ។

២៩. តាមទ្រឹស្ដី ដើមបណ្ដឹងរដ្ឋប្បវេណី មិនជំទាស់នឹងការបំបែកកិច្ចនីតិវិធីនៃសំណុំរឿង ០០២ ទេនៅក្នុងលក្ខខណ្ឌដែលការបំបែកកិច្ចនីតិវិធី មិនគិតត្រឹមតែក្ដីព្រួយបារម្ភលើភាពឆាប់រហ័យ ដោយមិនពិចារណាការលើលក្ខណៈវិនិច្ឆ័យជាមូលដ្ឋាន ប៉ុណ្ណោះទេ ដូចជា ប្រភេទ ភាពធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មនានា ចំនួននៃជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ តាមអង្គហេតុនៃឧក្រិដ្ឋកម្ម និងសិទ្ធិរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវស្ដាប់ចម្លើយ ក្នុងរយៈពេលសមស្រប ។

៣០. ទោះជាយ៉ាងណាក្ដី យើងខ្ញុំសូមគូសបញ្ជាក់ម្ដងទៀតថាយើងខ្ញុំបានឆ្លងកាត់នូវឧបសគ្គក្នុងការសម្រេចបាននូវដំណាក់កាលដំបូងក្នុងនៃការរៀបចំសំណងនេះ ។ ផ្ទុយទៅវិញ យើងខ្ញុំជឿជាក់ថា យើងខ្ញុំបានធ្វើការពិគ្រោះយោបល់ ដើមបណ្ដឹងរដ្ឋប្បវេណីគ្រប់គ្រាន់ហើយ និងអាច បង្ហាញពីចំណងចាំបាច់រវាងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានរឃើញថាមានពិរុទ្ធភាព និងព្យសនកម្ម ព្រមទាំងរវាង ព្យសនកម្ម និងវិធានការស្នើសុំក្នុងគោលដៅជួសជុលសំណង ទោះបីជាអង្គជំនុំជម្រះបានចេញដីការបំបែកកិច្ចដំណើការនីតិវិធីក៏ដោយ ។ អង្គជំនុំជម្រះបានបំបែកកិច្ចដំណើការនីតិវិធីជាសវនាការតូចៗលើ បណ្ដុំ

[7] សាលក្រមក្នុងសំណុំរឿង០០១ វាក្យខ័ណ្ឌ ៦៦៥។

[8] ដូចខាងលើ វាក្យខ័ណ្ឌ ៦៦៥។

នៃឧក្រិដ្ឋកម្មនានា ។ ដំបូងទាមទារចំណងរវាង ឧក្រិដ្ឋកម្មណាដែលនាំឲ្យមាន ព្យសនកម្មណាមួយ ហើយដែលអាចមានការផ្លាស់ប្តូរតាមឧក្រិដ្ឋកម្ម និងព្យសនកម្ម ។ ហេតុនេះ យើងមិនដឹងទេថា អ្នកណាខ្លះ ក្នុងចំណោម ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៣៨៥០ នាក់ដែលទទួលស្គាល់ក្នុងសំណុំរឿង ០០២ នឹងចូលរួមក្នុងសវនាការតូចៗដំបូងនោះទេ ។

៣១. ដូចដែលបានគូសបញ្ជាក់រួចហើយ ក្នុងសារណារបស់យើង ដើមបណ្តឹងរដ្ឋប្បវេណីវាយតម្លៃបានថា ការបំបែកកិច្ចដំណើការនីតិវិធី នាំឲ្យប៉ះពាល់ដល់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលផលប៉ះពាល់នោះវាចេញពី ការបំបែកកិច្ចដំណើការនីតិវិធីនេះ ដោយអវត្តមានពត៌មានលម្អិតលើ អត្ថន័យ និងពេលវេលានៃការជំនុំជម្រះតូចៗនានាខាងមុខ សម្រាប់ ដើមបណ្តឹងរដ្ឋប្បវេណីជាង ៣០០០ នាក់នឹងអាចត្រូវបានបដិសេធសិទ្ធិក្នុងការចូលរួម ។ យើងខ្ញុំបានស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ ជាបន្ទាន់នូវអ្វីដែលអង្គជំនុំជម្រះ មានបំណងនឹងធ្វើចំពោះ សវនាការក្រោយៗទៀត និងអត្ថន័យនៃ សវនាការក្រោយៗទៀតទាំងនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីសូមសូមរំលឹកថា ផលវិបាកមួយក្នុង ចំណោមផលវិបាកនានានៃការបំបែកកិច្ចដំណើការនីតិវិធី គឺនឹងប៉ះពាល់ដល់ផលប្រយោជន៍ទាមទារ សំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូចនេះ ដោយកែប្រែ ដែលកំណត់នៃសវនាការនោះ មានតែ ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ៧៥០ នាក់ក្នុងចំណោម ដើមបណ្តឹងរដ្ឋប្បវេណី ជាង៤០០០នាក់ នឹងមានផលប្រយោជន៍ក្នុងការប្តឹងទាមទារក្នុង ការជំនុំជម្រះលើកទីមួយ ។ ដូចគ្នាផងដែរ នេះគឺ ត្រឹមតែ ដើមបណ្តឹងរដ្ឋប្បវេណីជាង ៤០០០នាក់នោះទេ ដែលនឹងមានសិទ្ធិទាមទារសំណង ហើយបើ ទោះបីជា សំណងនៅ អ.វ.ត.ក ត្រូវតែជា សំណងមានលក្ខណៈផ្លូវចិត្ត និងសមូហភាពក៏ដោយ ។

៣២. ដូច្នេះ ជាចាំបាច់ត្រូវ តែមានការបញ្ជាក់នានាអំពីការបញ្ជាក់ជាបឋមផ្ទុះបញ្ចាំងនូវក្រុមរួមរបស់ដើម បណ្តឹងរដ្ឋប្បវេណី និងមិនមែនគម្រោងនានាពាក់ព័ន្ធដាច់ខាតទៅនឹង ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹង មានផលប្រយោជន៍ក្នុងការប្តឹង ចូលរួម និងទាមទារសំណង នៅពេលដែលអង្គជំនុំជម្រះបានបញ្ជាក់ពី ក្របខ័ណ្ឌនៃការជំនុំជម្រះលើកដំបូងនោះ ។

### ឃ. ដំណើរការពិគ្រោះយោបល់

៣៣. សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺកំពុងតែពិភាក្សាពិគ្រោះ យោបល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ១.៧០០នាក់ ដែលបានបញ្ចូលបន្ថែមនៅចុងខែមិថុនា ។ ហើយការពិភាក្សានេះគឺថាកំពុងតែបន្តទោះបីជាមានឧបសគ្គពាក់ព័ន្ធទៅនឹងខាងការទំនាក់ទំនង ការដឹកជញ្ជូនហើយវាមិនអាចលឿនហើយឬក៏ស្រួលដែរ។

៣៤. ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយគឺថាយើងព្យាយាមធ្វើម៉េចឲ្យមានការពិគ្រោះយោបល់ពេញលេញទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ នៅក្នុងដំណើរការពិគ្រោះយោបល់នេះគឺថាយើងគិតថាវាជាធាតុមួយដែលមិនអាចជំនួសបាននៃសំណងដែលថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មានសិទ្ធិហើយគាត់មានបង្ហាញនូវមនោសញ្ចេតនាដែលថាគាត់ពេញចិត្តចំពោះតុលាការនេះហើយគាត់នឹងពេញចិត្តចំពោះយុត្តិធម៌។ សហមេធាវីនាំមុខនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថាគាត់មានភាពធានាក្នុងចិត្តពាក់ព័ន្ធទៅនឹងសារៈសំខាន់ដែលខ្លួនបានផ្តល់ទៅលើដំណើរការពិគ្រោះយោបល់ដែលបានផ្តល់ជូនទៅដល់ច្បាប់ជាតិនិងអន្តរជាតិ។ពាក់ព័ន្ធទៅនឹងបញ្ហានេះហ្នឹងនៅក្នុងកថាខណ្ឌ១១នៃគោលការណ៍ជាមូលដ្ឋាននិងសេចក្តីណែនាំពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការទទួលបានដំណោះស្រាយនិងសំណងនៃជនជាប់ចោទដែលនៃការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិអន្តរជាតិនិងសិទ្ធិមនុស្សហើយគឺថាបើបានលើកឡើងហើយអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ ក្នុងលក្ខខណ្ឌសមភាព ហើយនិង ទទួលបានព័ត៌មានចាំបាច់ពាក់ព័ន្ធទៅនឹងការរំលោភ និងយន្តការនៃសំណង។

៣៥. អង្គការអន្តរជាតិ អ៊ីនធ័រ ណែសនធ័រ ហ្វ័រ ទ្រែនស៊ីស៊ិនណល ចាស្ទីស បានបញ្ជាក់យ៉ាងច្បាស់ថា គឺវិធានការសំណង គឺកើតចេញពីការពិគ្រោះយោបល់ពិតប្រាកដជាមួយនឹងជនរងគ្រោះ ដែលមានឱកាសក្នុងការទទួលបាននូវយុត្តិធម៌ និងទទួលបាននូវប្រសិទ្ធភាព។

៣៦. សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នឹងបន្តពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងក្របខ័ណ្ឌនៃដំណើរការពិគ្រោះយោបល់ ដោយគោរពទៅលើតួនាទីរបស់គាត់ក្នុងនាមជាភាគី នៅក្នុងរឿងក្តី ហើយនិងធ្វើយ៉ាងណាផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសំណាងក្នុងការទទួល ឃើញនូវអ្វីដែលខ្លួនចង់បាន នៅពេលដែលខ្លួនបានចូលរួមនៅក្នុងដោះស្រាយនូវការបង្កើតសំណើសុំ សំណងនេះ។ នៅពេលដែលយើងធ្វើដំណើរការតាមរបៀបនោះ គឺថាយើងមិនបានប៉ះពាល់ទៅដល់ ការបង្ហាញសំណង ដែលមានលក្ខណៈត្រឹមត្រូវ និងមានបញ្ជាក់ហេតុផលនៅចំពោះមុខអង្គជំនុំជម្រះ ទាំងនេះ។ ហើយទាំងអស់នេះ គឺវាពង្រឹងនូវឱកាសដែលថាវិធានការទាំងអស់នេះ គឺថាអាចត្រូវបាន ទទួលយកបាននៅចំពោះមុខច្បាប់។

## IV. ចម្លើយទៅនឹងសេចក្តីសង្កេតរបស់អង្គជំនុំជម្រះអំពីការបង្ហាញបឋមអំពីប្រភេទនៃសំណង ដែលមេធាវីនាំមុខមានបំណងស្នើសុំនៅក្នុងពាក្យសុំចុង ក្រោយ

៣៧. នៅក្នុងអនុស្សារណៈ E125 របស់ខ្លួននៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានកំណត់នូវ ក្របខ័ណ្ឌដែលខ្លួនចង់កំណត់ពាក់ព័ន្ធទៅនឹងដំណើការនៃការស្នើសុំសំណង។ អង្គជំនុំជម្រះ បានបង្ហាញ អំពីការសង្កេតបន្ថែមអំពីការបញ្ជាក់បឋមអំពីសំណងដែល មេធាវីនាំមុខបានបង្ហាញនៅពេលសវនាការ បឋម។ យើងឆ្លៀតឱកាសនោះដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃការសង្កេតទាំងនេះនិងផ្តល់ការបញ្ជាក់ បន្ថែមដែលយើងមានបំណងស្នើសុំ និងបញ្ជាក់អំពីកង្វល់របស់តុលាការ និងបញ្ហានានាដែលបានលើក ឡើងនៅក្នុងការបង្ហាញបឋមអំពីសំណងរបស់យើងខ្ញុំ។

### ក. អំពីការសហការជាមួយនឹងដៃគូរ

៣៨. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដឹងថាតាមរយៈវិធានផ្ទៃក្នុងបន្ទុក និងការ តាក់តែងគម្រោងនានាគឺមិនស្ថិតនៅលើមេធាវីនាំមុខតែប៉ុណ្ណោះនោះទេ។ ជាការពិតអង្គភាពគាំពារ ជនរងគ្រោះមានតួនាទីផងដែរក្នុងការរៀបចំអនុវត្តវិធានការមិនមែនបច្ចេកទេសតុលាការ និងរៀបចំ

គម្រោងសំណងនានាដោយសហការជាមួយអង្គការអន្តរការីស្របតាមវិធាន១២ស្ទួន និងវិធាន២៣ស្ទួនបី(ខ)។

៣៩. ដោយមូលហេតុនេះជាច្រើនខែមកហើយ ទន្ទឹមនឹងការសម្របសម្រួលនានាលើបញ្ហាផ្នែកច្បាប់ និងសំណុំរឿង មេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជួបប្រជុំផ្លាស់ប្តូរយោបល់ជាច្រើនលើកជាមួយនឹងប្រធានគម្រោងសំណងរបស់អង្គភាពគាំពារជនរងគ្រោះដើម្បីរៀបចំគម្រោងសំណងនានា។ ដោយមានការសម្របសម្រួលពីអង្គភាពគាំពារជនរងគ្រោះ ការងារកំណត់នូវគម្រោងសំណងនិងភាពដែលអាចធ្វើបាននៃសំណងត្រូវបានលើកឡើង។ ជាការពិតសំណងទាំងអស់នោះអាចត្រូវបានរៀបចំឡើងតាមរយៈគម្រោង ឬ កម្មវិធីដោយសហការជាមួយសង្គមស៊ីវិល អាជ្ញាធររាជរដ្ឋាភិបាល និងម្ចាស់ជំនួយនានា។ អង្គភាពគាំពារជនរងគ្រោះបានសហការគ្នាយ៉ាងជិតស្និតពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តគម្រោង។ ការសហការរបស់យើងទាំងពីរអង្គភាពកំពុងបន្ត និងត្រូវបន្តសហការគ្នាតទៅទៀតនាពេលអនាគត។

៤០. ក៏ប៉ុន្តែយើងត្រូវដឹងថាភារកិច្ចដែលផ្តល់ឲ្យមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាដល់អង្គភាពគាំពារជនរងគ្រោះគឺជាកិច្ចការយ៉ាងច្រើន ហើយដែលមិនដែលមានពីមុនមកនៅក្នុងតុលាការអន្តរជាតិ។ អាណត្តិអំពីសំណង ដែលផ្តល់ឲ្យយើងខ្ញុំជាធម្មតា គួរត្រូវអនុវត្តដោយអង្គភាពជំនាញដែលមានបុគ្គលិកជាច្រើន ថវិកាជាច្រើន ពេលវេលា និងបទពិសោធន៍ជាច្រើន។ ដើម្បីធានានូវការរៀបចំគម្រោងឲ្យបានលឿន ឆាប់រហ័សដែលមិនមែនជាគម្រោងជានិម្មិតរូប និងមានអត្ថន័យដល់ដើមបណ្តឹងរដ្ឋប្បវេណីបាន វាគួរតែអង្គភាពគាំពារជនរងគ្រោះមានក្រុមធ្វើការមួយដែលមានបុគ្គលិកគ្រប់គ្រាន់។

**ខ. ការបង្កើតមូលនិធិសំណង**

៤១. នៅក្នុងអនុស្សារណៈ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះបញ្ជាក់ថា *"ការបង្កើតមូលនិធិសំណងក៏ដូចជា សំណងជាថវិកាដល់ឯកជនមិនចូលនៅក្នុងក្របខណ្ឌនៃសំណងដែលអាចផ្តល់ឡើងដោយ **អ.វ.ត.ក** ឡើយ"*។ នេះគឺជាចំនុចដែលមាននៅក្នុងសាលក្រមរបស់ឌុច និងនៅក្នុងវិធាន ២៣ ស្ទួន៤(១)។ វាហាក់ដូចជាថា យ៉ាងហោចណាស់ក៏យើងមិនអាចឈរលើមូលដ្ឋានណាមួយក្នុងចំណោមប្រភពមូលដ្ឋានទាំងពីរនេះដើម្បីបដិសេធ ការស្នើសុំថវិកាជួសជុលសំណងដែលត្រូវបានបង្កើតឡើងជាក់លាក់ដើម្បីផ្តល់ជាថវិកាទៅដល់សំណងជាដែលជាផ្លូវច្បាប់អាចធ្វើទៅកើតនោះទេ។ យើងខ្ញុំសូមបញ្ជាក់ថា អ្វីដែលយើងខ្ញុំស្នើសុំគឺជាការបង្កើតនូវអង្គភាពមិនមែនរដ្ឋាភិបាលមួយ ឬក៏អង្គភាពដែលមានលក្ខណៈពាក់កណ្តាលរដ្ឋបាលមួយ ឬមានទម្រង់ដែលនឹងត្រូវបង្កើតឡើងដូចជាក្នុងនាមជាអង្គភាពឯករាជ្យ និងដាច់ដោយឡែកពីក្របខ័ណ្ឌនៃ**អ.វ.ត.ក**។ ក្របខ័ណ្ឌរបស់វានឹងមានគោលដៅអនុវត្ត/ផ្តល់មូលនីធិដើម្បីធានាការអនុវត្តគម្រោងសំណងនេះ ដែលសម្រេចដោយតុលាការនេះគម្រោងនេះនឹងត្រូវលើកលំអិតក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ នាពេលក្រោយ។

### គ. ចំពោះវិធានការដែលតម្រូវឲ្យមានការឯកភាពពីរាជរដ្ឋាភិបាល

៤២. ឆ្លើយតបចំពោះផ្នែកមួយនៃអនុស្សារណៈថ្ងៃទី២៣ខែកញ្ញាឆ្នាំ២០១១ដែលតាមរយៈនោះអង្គជំនុំជម្រះបានសង្កេតឃើញថា *"វិធានមួយចំនួនដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីអាចស្ថិតនៅខាងក្រៅក្របខ័ណ្ឌនៃវិធានដែលអាចត្រូវបានអនុញ្ញាតដោយ**អ.វ.ត.ក**ដោយសារវាស្ថិតនៅក្នុងវិស័យនៃសមត្ថកិច្ចរបស់អាជ្ញាធរដ្ឋាភិបាល"* ។នៅក្នុងកថាខណ្ឌដដែលអង្គជំនុំជម្រះបានលើកឡើងដូចជា "ការបង្កើតឡើងនូវថ្ងៃអនុស្សាវរីយ៍ដែលមិនអាចសម្រេចបានដោយអង្គជំនុំជម្រះដោយមូលហេតុនៅក្នុងនាមជាសំណងវាត្រូវមានការសម្រេចឬក៏ត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា"។

៤៣. មេធាវីនាំមុខសូមកត់សម្គាល់ដោយពេញចិត្តថាអង្គជំនុំជម្រះបានទទួលស្គាល់ថាសំណើបឋមដែលបានលើកឡើងនេះ ប្រសិនបើត្រូវការឲ្យមានការអនុញ្ញាតជាផ្លូវការឬការព្រមព្រៀងពីរដ្ឋាភិបាលវាមិនត្រូវ

ការជាចាំបាច់ពីសកម្មភាពណាមួយពីរដ្ឋាភិបាលឡើយ។សកម្មភាពទាំងអស់នេះត្រូវអនុញ្ញាតដោយយ៉ាងពេញលេញដោយវិធានផ្ទៃក្នុងមុនមុនហើយនៅក្នុងអត្ថបទវិធានផ្ទៃក្នុងបច្ចុប្បន្ននៃវិធាន២៣ស្ទួន ៣(ខ) និយាយថាអង្គជំនុំជម្រះអាចទទួលស្គាល់នូវទម្រង់ជាក់លាក់ដែលជាចម្លើយសមស្របទៅនឹងសំណើសុំសំណងដែលត្រូវរៀបចំឡើងឬកំណត់ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ។

៤៤. ចំពោះគម្រោងដូចជាការបង្កើតនូវថ្ងៃរំលឹកវិញ្ញាណក្ខ័ន្ធ យើងនឹងមិនស្នើសុំថាអង្គជំនុំជម្រះកំណត់ឲ្យមានការអនុវត្តពីរដ្ឋាភិបាលឡើយ។ផ្ទុយទៅវិញមានការខំប្រឹងប្រែងពីអង្គភាពគាំពារជនរងគ្រោះក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបាននូវថ្ងៃបែបនេះមុននឹងសម្រេចពេលចុងក្រោយទៅដល់ការដាក់លើកជាគម្រោងសុំឲ្យមានការទទួលស្គាល់ពីតុលាការជៀសវាងការមិនទទួលស្គាល់ពីតុលាការ។ចំពោះវិធានផ្ទៃក្នុងវាមានភាពស្របគ្នាទៅនឹងភារកិច្ចដែលថាមេធាវីនាំមុខបង្ហាញអំពីសំណើសុំទាំងអស់នេះនិងអង្គជំនុំជម្រះទទួលស្គាល់សំណើទាំងនេះ។

**ឃ. ការបញ្ជាក់បន្ថែមជាចាំបាច់សម្រាប់ទំនាននានាដ៏នៃទៀត**

៤៥. នៅក្នុងអនុស្សារណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដូចខាងក្រោម៖ *សំណើនានាផ្សេងទៀតដែលស្នើសុំមិនមានភាពជាក់លាក់គ្រប់គ្រាន់ដើម្បីអាចធ្វើសេចក្តីសង្កេតដោយមានអត្ថន័យបានឡើយនៅក្នុងដំណាក់កាលនេះ។* ចម្លើយនេះមានធាតុពីរដែលនាំឲ្យមានការផ្តល់ចម្លើយ ៖ ជាបឋមគឺនិយមន័យនៃពាក្យជាក់លាក់គ្រប់គ្រាន់ បន្ទាប់មកគឺជាការដែលចាំបាច់ឬសមស្របឲ្យអង្គជំនុំជម្រះបង្ហាញអំពីសេចក្តីសង្កេតឲ្យមានអត្ថន័យនៅក្នុងដំណាក់កាលនេះ។

៤៦. ដោយមិនទាន់បានទទួលនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងករណី ០០១ មេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចយោងទៅសាលក្រមករណី០០១ ឬក៏វិធាន

ផ្ទៃក្នុងដើម្បីកំណត់អំពីក្របខណ្ឌនៃគម្រោងដើម្បីឱ្យវាមានភាពជាក់លាក់បានឡើយ[9]។ នៅក្នុងសាលក្រមករណី***ឌុច***អង្គជំនុំជម្រះបានប្រកាសដូចតទៅ៖ *ដើម្បីឱ្យមានសំណងមួយអាចត្រូវបានផ្ដល់ជាដំបូងត្រូវបញ្ជាក់ ឱ្យបានច្បាស់អំពីប្រភេទនៃវិធានការដែលបានស្នើសុំ[10]*។ នៅក្នុងសេចក្ដីសម្រេចទាក់ទងទៅនឹងបណ្ដឹងរដ្ឋប្បវេណីអង្គជំនុំជម្រះបានបដិសេធសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនដោយមូលហេតុខ្វះភាពជាក់លាក់ និងទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនបានបង្ហាញអំពីអ្វីដែលជាសំណើមានលក្ខណៈជាក់លាក់គ្រប់គ្រាន់នោះឡើយ។ គួរឱ្យកត់សម្គាល់ថាវិធានផ្ទៃក្នុង***កំណែប្រែទី៣*** ឬក៏ទោះជាសេចក្ដីណែនាំពាក់ព័ន្ធនីតិវិធីនៅក្នុងការដាក់នីតិវិធីនៃសំណងនិងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចុងក្រោយក៏ដោយ ក៏មិនមានកំណត់នូវលក្ខណៈវិនិច្ឆ័យក្នុងការបញ្ជាក់ឱ្យបានជាក់លាក់នោះឡើយ។ ជាការពិតអង្គជំនុំជម្រះមិនបានបង្ហាញនូវវិធានណាមួយយុត្តិសាស្ត្រណាមួយ ឬក៏ប្រភពគតិយុត្តណាមួយដើម្បី អនុញ្ញាតឱ្យលាតត្រដាងនូវការពិចារណានានាដែលអនុញ្ញាតឱ្យមានការជឿជាក់អំពីភាពជាក់លាក់នេះបានឡើយ។

៤៧. ផ្ទុយពីនេះវាជាការពិតដែលថាវិធានផ្ទៃក្នុង*(វិធានកែប្រែទី៨)*ប្រើប្រាស់នូវពាក្យ *"បញ្ជាក់បន្ថែម[11] និងជាក់លាក់[12]"*ហើយមិនបានផ្ដល់នូវសញ្ញាណការពន្យល់ពាក្យឬក៏ការពន្យល់និយមន័យនូវអ្វីដែលបង្កើតបានជាពាក្យសុំជាក់លាក់គ្រប់គ្រាន់នោះឡើយហើយអង្គជំនុំជម្រះក៏មិនបានផ្ដល់នូវការបកស្រាយរបស់ខ្លួនទាក់ទងទៅនឹងចរិកលក្ខណៈដើម្បីអនុវត្តនេះផងដែរ។ នៅក្នុងអនុស្សារណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ

---

[9] សាលក្រមក្នុងសំណុំរឿង០០១ វាក្យខ័ណ្ឌ ៦៦៥ (មិនមានគូសបន្ទាត់ទេក្នុងច្បាប់ដើម)។

[10] ដូចយោងខាងលើ វាក្យខ័ណ្ឌ ៦៦៨ ៦៦៩ និង៦៧២ ដល់ ៦៧៤។

[11] សូមមើល ២៣វិធានស្ទួន ពីរចំណុច ខ នៃវិធានផ្ទៃក្នុង អ.វ.ត.ក *(វិធានកែប្រែទី៨)* (សារណា .... ខ) បង្ហាញថា សំណងឆ្លើយតបនឹង អ្វីដែលសំណងឆ្លើយតបនឹង ព្យសនកម្ម ដែលទទួលរង និងច្បាស់លាស់ បើចាំបាច់ ក្រុមដើមបណ្ដឹររដ្ឋប្បវេណីក្នុងក្រុមរួមដែលទទួលរងព្យសនកម្ម) (គ្មានគូសបន្ទាត់ពីក្រោមទេក្នុងឯកសារដើម)

[12] សូមមើល ២៣វិធានស្ទួន ពីរចំណុច គ នៃវិធានផ្ទៃក្នុង (ពាក់ព័ន្ធសំណងនីមួយៗ អង្គជំនុំជម្រះអាច ជូន .... ទទួលស្គាល់ថាគម្រោងជាក់លាក់បង្កើតជាចម្លើយតបមួយដ៏សមស្របទៅនឹងសំណើសុំសំណង ) (គ្មានគូសបន្ទាត់ពីក្រោមទេក្នុងឯកសារដើម)។

២០១១ អង្គជំនុំជម្រះបានរំលឹកដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអំពីកាតព្វកិច្ចនៅក្នុងការបង្ហាញជាបឋមនៃសំណងម្ដងទៀតដោយមិនបានផ្ដល់និយមន័យនៃពាក្យនេះ ឬក៏ បំភ្លឺផ្សេងៗឡើយ[13]។ ដោយមិនមានការបញ្ជាក់ពីអង្គជំនុំជម្រះឬក៏វិធានផ្ទៃក្នុងឱ្យបានជាក់ច្បាស់ ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានការកំណត់សម្គាល់ជាក់លាក់ ឬក៏ទិសដៅជាក់លាក់ដើម្បីរៀបចំពាក្យសុំសំណងរបស់ខ្លួនឱ្យស្របទៅនឹងការទន្ទឹងរង់ចាំរបស់អង្គជំនុំជម្រះឡើយ។

៤៨. វិធាននីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បង្ហាញថាតុលាការអន្តរជាតិត្រូវផ្ដល់នូវការជាក់លាក់អំពីសំណើនានានៃសំណង។ យោងតាមវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាន៩៤(១)(ខ)នេះ *"ពាក្យសុំសំណងត្រូវតែមានការអត្ថាធិប្បាយអំពីការខូចខាត ការបាត់បង់ ព្យសនកម្ម[14] ក៏ដូចជាពាក្យសុំការស្ដារនីតិសម្បទា ឬក៏ សំណងដែលមានទម្រង់អ្វីផ្សេងទៀត"*[15]។ គ្មានកន្លែងណាមួយដែលតម្រូវឱ្យមានពាក្យសុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ឬក៏មានការផ្ដល់ឱ្យមានភាពជាក់លាក់ត្រូវបានប្រើប្រាស់នោះទេយោងតាមវិធាននេះ[16] វាជាក់ច្បាស់ណាស់ថានៅក្នុងករណីដែលពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មានភាពចាំបាច់យោងទៅលើព្យសនកម្ម[17] អង្គជំនុំជម្រះ

---

[13] អនុស្សារណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ។

[14] វិធាន៩៤(១)(ខ)នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[15] វិធាន៩៤(១)(ច)នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[16] សូមមើលផងដែរសេចក្ដីសម្រេច នៃមហាសន្និបាតសាមញ្ញ ឯកសារអង្គការសហប្រជាជាតិលេខ A/RES/60/147 ចុះថ្ងៃទី២១ មីនា ២០០៦ វាក្យខណ្ឌទី ១៥ ដែលបានបញ្ជាក់ថា ក្រុមប្រឹក្សាសិទ្ធិមនុស្សមិនតម្រូវឱ្យមានកម្រិតខ្ពស់នៃការបញ្ជាក់ទេ។ ពាក់ព័ន្ធនឹងសំណង វាហាក់ដូចជា ក្ដីបារម្ភសំខាន់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះគឺតម្រូវនូវអ្វីដែលថាសំណង ត្រូវឆ្លើយតបនឹងភាពធ្ងន់ធ្ងរនៃការរំលោភ បំពាន និងព្យសនកម្មដែលទទួលរង ។

[17] លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិទីក្រុង រ៉ូម ចុះថ្ងៃទី ១៧ សីហា ១៩៩៨ Recueil des Trait‟s de l'ONU, vol. ២១៨៧ ។ មាត្រា ៧៥ ២) (តុលាការអាចចេញដីកាបង្គប់ឱ្យបុគ្គលដែលត្រូវបានកាត់ទោសដោយចង្អុលបង្ហាញពីសំណងដែលត្រូវផ្ដល់ឱ្យជនរងគ្រោះ ឬអ្នកទទួលសិទ្ធិរបស់ពួកគេ ។ សំណងនេះអាចផ្ដល់ក្រោមទម្រង់ជាអាទិ ការសងការខូចខាតវិញ ការជួសជុល ការស្ដានីតិសម្បទា)។

ត្រូវតែទទួលថាវាអាចទទួលយកបាន[18]។ វិធានទាំងអស់នេះមិនទាន់ត្រូវបានយកមកអនុវត្តនៅឡើយ នៅក្នុងការអនុវត្តជាក់ស្តែង និងវាអត់ទាន់មានយុត្តិសាស្ត្រដែលអនុញ្ញាឲ្យបកស្រាយថា តើតុលាការព្រហ្មទណ្ឌអន្តរជាតិ បកស្រាយចរិកលក្ខណៈដែលអនុវត្តទៅនឹងពាក្យសុំនៃសំណង ឬ យ៉ាងណានោះទេ។ ដូច្នេះវានៅតែជាពាក្យ ពាក្យដែលគ្មានភាពច្បាស់លាស់គ្រប់គ្រាន់នៃវិធានផ្ទៃក្នុង ហើយពាក្យសុំសំណង មិនអាចត្រូវតម្រូវឲ្យឆ្លើយតបទៅនឹងចរិកលក្ខណៈខ្ពស់នៃភាពជាក់លាក់នោះឡើយ។

៤៩. ខុសអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការអន្តរ-អាមេរិកកាំងនៃសិទ្ធិមនុស្សបានផ្តល់នូវយុត្តិសាស្ត្រផ្ទុយ ទៅនឹងចរិកលក្ខណខ្ពស់មែនទែននៃភាពជាក់លាក់ដែលតម្រូវដោយចៅក្រមសាលាដំបូង។ តាមរយៈយុត្តិសាស្ត្រនេះនៃតុលាការជាន់ខ្ពស់អាមេរិកកាំង ជនរងគ្រោះមិនចាំបាច់ស្នើសុំសំណងដោយបញ្ជាក់ឲ្យមានភាពជាក់លាក់ខ្ពស់នោះទេ។ នៅក្នុងសំណុំរឿង Mapiripan Massacre V. Columbia ចៅក្រមបានសន្និដ្ឋានដូចខាងក្រោម៖ ដោយពិនិត្យឃើញភាពធ្ងន់ធ្ងរនៃអង្គហេតុនៅក្នុងករណីនេះដែលមានដូចជា៖ អំពើមនុស្សឃាតដោយចេតនា ការបាត់ខ្លួន និងការបញ្ជូនមនុស្សដោយបង្ខំនៃជនជាតិ Mapiripan ស្ថានភាពនៃនិទ្ទនភាពពាក់កណ្តាលនៃចារី ភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបង្កើតមានដល់ជនរងគ្រោះ ការប្រែប្រួលយ៉ាងខ្លាំងក្នុងលក្ខខណ្ឌរស់នៅ និងផលវិបាកសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្សេងទៀត វាហាក់ដូចជាចាំបាច់តាមលក្ខខណ្ឌសមធម៌ក្នុងការផ្តល់នូវសំណងផ្នែកហិរញ្ញវត្ថុអាស្រ័យទៅតាមព្យសនកម្មតែមិនមានលក្ខណហិរញ្ញវត្ថុ[19]។ នៅក្នុងសេចក្តីសម្រេចនេះចៅក្រមបាននិយាយថារដ្ឋ

---

[18] សូមមើលផងដែរ សេចក្តីសម្រេច នៃមហាសន្និបាតសាមញ្ញ ឯកសារអង្គការសហប្រជាជាតិលេខ A/RES/60/147 ចុះថ្ងៃទី២១ មីនា ២០០៦ វាក្យខណ្ឌទី ១៥ ដែលបានបញ្ជាក់ថា ក្រុមប្រឹក្សាសិទ្ធិមនុស្សមិនតម្រូវឲ្យមានកម្រិតខ្ពស់នៃការបញ្ជាក់ទេ។ ពាក់ព័ន្ធនឹងសំណង វាហាក់ដូចជា ក្តីបារម្ភសំខាន់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះគឺតម្រូវនូវអ្វីដែលថាសំណង ត្រូវឆ្លើយតបនឹងភាពធ្ងន់ធ្ងរនៃការរំលោភ បំពាន និងព្យសនកម្មដែលទទួលរង)... ។

[19] សំណុំរឿង Mapiripan Massacre V. Columbia សំណង និងសោហ៊ុយ តុលាការសិទ្ធិមនុស្សអន្តរអាមេរិច សេរីលេខ No. ១៣៤ ចុះថ្ងៃទី ១៥កញ្ញា ២០០៥ សេរីលេខ C No. ១៣៤ វាក្យខណ្ឌ ២៨៥ ។ មើលផងដែររឿងក្តី *Case of Acosta Calder€n* ដូចយោងកំណត់សម្គាល់ខាងលើលេខ៧ ពី១៥៩ ដល់ ១៦០។ មើលផងដែររឿងក្តី*Case of Caesar ,*ដូចយោងកំណត់សម្គាល់

ខ្លឹមសារជាក់លាក់ជាបឋមស្តីពីសំណងដែលសហមេធាវីនាំមុខតំណាង

ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំ នាពេលសវនាការថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១

ត្រូវតែស្ថាបនាក្នុងរយៈពេលមួយឆ្នាំនូវស្តូបសមស្រប និងមានលក្ខណៈថ្លៃថ្នូរជាការរំលឹកអនុស្សាវរីយ៍ ទៅដល់ការសម្លាប់រង្គាលដល់ពួកMapiripanដែលត្រូវបង្កើតឡើងនៅក្នុងទីកន្លែងសាធារណៈនៅ Mapiripan[20]។ចៅក្រមមិនបានបង្ខំឲ្យជនរងគ្រោះនៅក្នុងការផ្តល់នូវការបញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹង ចំនួនប្រភេទនៃស្តូបរំលឹកវិញ្ញាណខន្ធដែលបានសាងសង់នោះឡើយទោះជាទីកន្លែងដែលត្រូវសាងសង់ ឬក៏តម្លៃដែលបញ្ជាក់បន្ថែមនោះ[21]ក៏ដោយមិនដូចនៅក្នុងករណី០០១ដែលអង្គជំនុំជម្រះបានឆ្លើយតបទៅ នឹងពាក្យសុំស្រដៀងគ្នានេះអំពីស្តូបនិងចេតិយដែលស្នើសុំដោយភាគីនោះឡើយ។

៥០. ដោយហេតុថាអង្គជំនុំជម្រះមិនដែលបានបញ្ជាក់ ផ្តល់និយមន័យនូវអ្វីដែលខ្លួនបាននិយាយអំពីភាពជាក់លាក់គ្រប់គ្រាន់ ឬក៏ ឲ្យមានការជាក់លាក់ហើយដោយហេតុថា វាក្យស័ព្ទទាំងនេះមិនដែលមានពីមុននៅក្នុងច្បាប់អន្តរជាតិ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទាយថា តើអ្វីដែលខ្លួនត្រូវបង្ហាញដើម្បីបំពេញចិត្តទៅនឹងចរិកលក្ខណៈដែលកំណត់ដោយអង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវមានការទទួលខុសត្រូវបន្ថែមពីបញ្ហានេះឡើយ។ តែទោះជាយ៉ាងណាក៏ដោយសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលកំពុងមានបញ្ហា ហើយសំណងទាំងអស់នោះត្រូវមានព័ត៌មានគ្រប់គ្រាន់អំពីអ្វីដែលចៅក្រមកំពុងចង់បាន ហើយវាត្រូវតែស្របទៅនឹងច្បាប់អន្តរជាតិ។

### ឃ. វិធានដែលស្ថិតនៅក្នុងក្របខណ្ឌតុលាការនៃ អ.វ.ត.ក

៥១. ដើម្បីបញ្ចប់អំពីប្រភេទចុងក្រោយនៃពាក្យសុំទាក់ទងទៅនឹងសំណង អង្គជំនុំជម្រះបានផ្តល់នូវសេចក្តីសង្កេតពាក់ព័ន្ធទៅនឹងវិធានការដែលអង្គជំនុំជម្រះពិនិត្យឃើញថាស្ថិតនៅក្នុងក្របខណ្ឌតុលាការនៃ

---

ខាងលើលេខ១៧៤ វាក្យខណ្ឌ១២៦ ។ មើលផងដែររឿងក្តី*Case of Huilca Tecse* ដូចយោងកំណត់សម្គាល់ខាងលើលេខ២៧៤ វាក្យខណ្ឌ ៩៧។

[20] ដូចលេខយោងខាងលើ វាក្យខណ្ឌ ៣១៥។

[21] សាលក្រមក្នុងសំណុំរឿង០០១ វាក្យខ័ណ្ឌ ៦៧២ ។

**អ.វ.ត.ក** វាអាចមានជាការផ្សព្វផ្សាយនៃសាលក្រមនៅក្នុងករណី០០២ និងការប្រមូលផ្តុំនូវបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់[22]។

៥២. មេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឯកភាពគ្នាថានេះគឺជាចំនុចចាប់ផ្តើមដែលមានតម្លៃខ្ពស់សម្រាប់សំណងនានា ហើយថាវិធានទាំងអស់នេះស្ថិតនៅក្នុងក្របខណ្ឌគតិយុត្តនៃ **អ.វ.ត.ក**។ ហើយវាគួរតែអាចទទួលយកបាននៅក្នុងក្របខណ្ឌនៃ ០០២។

៥៣. ស្នើសុំសំណងតែប៉ុននេះដែលមានលក្ខណកម្រិតធ្ងន់ធ្ងរបំផុតគឺជាការធ្វើឲ្យប៉ះពាល់ដល់គោលការណ៍គតិយុត្តជាមូលដ្ឋានដែលតម្រូវឲ្យមានការជួសជុលសំណងដល់ព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណីលើសពីនេះទៅទៀតវាគឺជាវិធានការដែលមានលក្ខខណ្ឌឃ្លាតឆ្ងាយពីប្រភេទរួមនានានៃសំណងដែលបង្កើតឡើងនៅក្នុងក្របខណ្ឌនៃវិធានផ្ទៃក្នុង និងនៅក្នុងក្របខណ្ឌអន្តរជាតិ។

៥៤. គោលការណ៍ចំបងទាក់ទងទៅនឹងសិទ្ធិក្នុងការទទួលការប្តឹងទាមទារ និង ការទទួលបាននូវសំណងរបស់ជនរងគ្រោះនៃការរំលោភបំពានជាក់ស្តែងនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងការរំលោភបំពានធ្ងន់ធ្ងរអំពីច្បាប់មនុស្សធម៌អន្តរជាតិបានរំលឹកថាសំណងត្រូវតែសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងព្យសនកម្មដែលបានទទួល[23]។ ទោះជាតុលាការនេះប្រឈមមុខទៅនឹងការលំបាកជាច្រើនក៏ដោយនៅក្នុងការផ្តល់សំណង តុលាការត្រូវតែមានលទ្ធភាព និងអាចផ្តល់សំណងដែលមានសារៈសំខាន់ផ្សេងទៀតក្រៅពីការបោះពុម្ពផ្សាយ សាលក្រមដែលជនជាតិកម្ពុជាជាច្រើនគ្មានលទ្ធភាពក្នុងការទទួលបាន ឬក៏យល់ដឹង។

## VI. ព័ត៌មានបច្ចុប្បន្នភាព និងពត៌មានបន្ថែមអំពីសេចក្តីបញ្ជាក់បឋមនៃសំណង

---

[22] អនុស្សារណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទំព័រ ៤។

[23] គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានការជួសជុល និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ មាត្រា ១៥។

៥៥. បន្ទាប់ពីទទួលបាននូវកាលវិភាគដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ សំណើរសុំនីមួយៗរបស់ក្រុមមេធាវីចំនួនទាំងអស់ ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២ វិស័យចំនួនបួនដែលមានសំណងនៅក្នុងនោះគឺ (១) ការរំលឹក/ការគោរពវិញ្ញាណក្ខ័ណ (២) ការស្តារនីតិសម្បទា (៣) ការចងក្រងឯកសារ/ការអប់រំ (៤) សំណើផ្សេងៗទៀត។នៅក្នុងប្រភេទផ្សេងនៃសំណើរទាំងអស់នោះគេអាចរៀបចំវាជាទៅជាគម្រោងដោយសារថាការពិភាក្សាកំពុងតែដំណើរការនៅឡើយអ្វីដែលនឹងផ្តល់ជូននាពេលនេះគឺជាការអធិប្បាយជាបឋមអំពីខ្លឹមសារនៃគម្រោងនីមួយៗ។

## ក. ប្រភេទទីមួយ ÷ ការរំលឹក/ការគោរពវិញ្ញាណខន្ធ

៥៦. ការរំលឹក និងការគោរពវិញ្ញាណខន្ធ នៅក្នុងនោះមានវិធានការនៃសំណងជាច្រើនដែលមានគោលដៅគោរពវិញ្ញាណខន្ធដល់មរណភាពរបស់ជនរងគ្រោះដោយផ្តល់នូវទីកន្លែងសម្រាប់ធ្វើការរំលឹកវិញ្ញាណ និងពិចារណា។ ដោយធ្វើការច្របាច់បញ្ចូលគ្នានូវសំណើនីមួយៗចំនួន២៨ ដែលដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនានា សំណើទាំងអស់នោះអាចចាត់ទុកជាអនុប្រភេទផ្សេងៗគ្នានៃការរំលឹកវិញ្ញាណក្ខ័ណដែលនៅក្នុងនោះមាន៖ (១) ថ្ងៃនៃការចងចាំ (២) ចេតិយ៍ និង*ស្តូប*/បូជនីយដ្ឋាន (៣) ការប្រារព្ធពិធី និង (៤) ការរក្សាទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម។

៥៧. គម្រោងទីមួយមានឈ្មោះថា៖ *"គម្រោងគស្នីមគិដើម្បីបង្កើតឲ្យមានថ្ងៃចងចាំជាតិ និង អន្តរជាតិ"*។ គម្រោងនេះមានគោលដៅបង្កើតឲ្យមានថ្ងៃចងចាំមួយដើម្បីមានការទទួលស្គាល់ជាអចិន្ត្រៃយ៍ និង ជានិម្មិតរូប ហើយជាការរំលឹកការចងចាំនៃឧក្រិដ្ឋកម្មបានកើតឡើងនៅសម័យខ្មែរក្រហម។សំណងនេះនឹងបានជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និង អាចបង្កើតឲ្យមានបមួយថ្ងៃក្នុងមួយឆ្នាំដែលដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាប្រជាជនកម្ពុជាអាចជួបគ្នា និងរៀបចំពិធីបុណ្យតាមសាសនា ឬ ក៏មិនមានលក្ខណៈសាសនាសម្រាប់ជនរងគ្រោះ និងសាច់ញាតរបស់គាត់ទៅតាមជំនឿ និងវប្បធម៍របស់ខ្លួន។ សំណងនេះនឹងត្រូវផ្តល់ផលប្រយោជន៍ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីដូចដែលវាអាចជួយ

ដើមបណ្តឹងរដ្ឋប្បវេណីស្តារនូវសេចក្តីថ្លៃថ្នូរនិងទទួលពីរដ្ឋនិងសហគមន៍អន្តរជាតិដោយការទទួលស្គាល់នូវថ្ងៃជាផ្លូវការមួយនៅក្នុងការគោរពវិញ្ញាណខន្ធការធ្វើការបួងសួងនិងរៀបចំពិធីបុណ្យរំលឹកទៅដល់អ្នកដែលគាត់ស្រលាញ់។

៥៨. រហូតមកដល់ពេលនេះមិនទាន់មានការព្រមព្រាងគ្នាអំពីថ្ងៃណាមួយច្បាស់លាស់នៅក្នុងការបង្កើតថ្ងៃចងចាំនេះនៅឡើយទេ។ក្រុមមេធាវីផ្សេងៗបានស្នើថាថ្ងៃណាមួយសមស្របគួរតែត្រូវបានបង្កើតឡើងសម្រាប់ថ្ងៃចងចាំនេះមេធាវីផ្សេងៗបានស្នើថាវាអាចជាថ្ងៃបន្ថែមទៅលើថ្ងៃភ្ជុំបិណ្ឌឬក៏ថ្ងៃទី១៧ខែមេសា វាក៏អាចជាថ្ងៃ២០ឧសភាផងដែរ។ ការពិភាក្សាគ្នាលើបញ្ហានេះនឹងត្រូវបន្ត។ ក្រៅពីនោះមានក្រុមមួយចំនួនដែលស្នើសុំឲ្យមានថ្ងៃចងចាំសម្រាប់តែឧក្រិដ្ឋកម្មមួយចំនួនដែលទទួលរងដូចជាការរៀបការដោយបង្ខំ។ ការពិគ្រោះយោបល់បន្ថែមទៀតនិងត្រូវការដើម្បីឲ្យគម្រោងនេះកាត់តែរីកចម្រើនកំណត់ថ្ងៃមួយឲ្យជាក់លាក់និងវិធីនៅក្នុងការគោរពវិញ្ញាណខន្ធជូនជនរងគ្រោះនេះ។គម្រោងនេះត្រូវពាក់ព័ន្ធទៅនឹងរដ្ឋាភិបាល ឬក៏សហគមន៍អន្តរជាតិដើម្បីបង្កើតឲ្យមានថ្ងៃជាតិនិង/ឬ អន្តរជាតិមួយក្នុងការគោរពវិញ្ញាណខន្ធ។

៥៩. គម្រោងទី២នៃសំណងគឺជាគម្រោងសាងសង់ចេតី និង/ឬ ស្តូប/បូជនីយដ្ឋានដែលគ្មានលក្ខណៈសាសនា។ គម្រោងនេះត្រូវបានស្នើសុំដោយស្ទើតែគ្រប់ក្រុមមេធាវីទាំងអស់។ ការសាងសង់ស្តូបនេះគឺធ្វើឡើង ដើម្បីរំលឹកទៅដល់វិញ្ញាណក្ខណរបស់ជនរងគ្រោះដែលផ្តល់ឱកាសដល់ជនរងគ្រោះ និងក្មេងជំនាន់ក្រោយដើម្បីរំលឹកអំពីជនរងគ្រោះនៃរបបខ្មែរក្រហមតាមបែបបទមួយដែលមានលក្ខណៈយូរអង្វែង និងជាសម្ងហភាព។

៦០. គោលដៅនៃសំណង់នេះនឹងផ្តល់ជាប្រយោជន៍ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក៏ដូចជាជនរងគ្រោះ និងជនជាតិកម្ពុជាគ្រប់រូប។ ទោះជាយ៉ាងណាក៏ដោយក្រុមជាក់លាក់មួយចំនួនត្រូវតែបានស្តាប់ដោយពួកគាត់ស្នើសុំឲ្យមានសំណងជាក់លាក់សម្រាប់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីរបស់

ពួកគាត់។ ជាឧទាហរណ៍ ក្រុមមេធាវី Maat ស្នើសុំបង្កើតមជ្ឈមណ្ឌលសម្រាប់លើកទឹកចិត្តស្មារតីប្រជាជនកម្ពុជា ដែលជាទីកន្លែងមួយនៃការជំរុញនូវភាពសន្ដោសប្រណីគ្នា ។ មជ្ឈមណ្ឌលសម្រាប់លើកទឹកចិត្តស្មារតី ប្រមូលផ្ដុំនូវ ឯកសារគ្រប់ប្រភេទ (សៀវភៅសាសនា និងសៀវភៅធម៌ ឯកសារប្រវត្តិសាស្ត្រ) និងរាល់កម្មវត្ថុនៃលទ្ធិ ទាក់ទងនឹងទម្រង់ផ្សេងៗនៃជំនឿដែលអនុវត្តនៅកម្ពុជា ។ មានការពិភាក្សាមួយចំនួនទាក់ទងទៅនឹង ថាតើទំរង់នៃសំណងជាក់លាក់អ្វីខ្លះអំពីស្តូបឬក៏ចេតីយ៍គួរតែមាន ឬមួយក៏ត្រូវសាងសង់នៅទីកណ្តាលនៃខេត្តនីមួយៗ ឬក្នុងទម្រង់ជាការសាងសង់នៅតាមស្រុកពាសពេញផ្ទៃប្រទេស ។ ខ្លះទៀតយល់ឃើញថា វាគួរតែសាងសង់ចេតីយ៍ក្នុងនាមជាសំណងផ្លូវចិត្ត និងសមូហភាពសម្រាប់ ដើមបណ្តឹងរដ្ឋប្បវេណី ថ្វីបើ ដើមបណ្តឹងរដ្ឋប្បវេណី ដ៏ច្រើនក៏អាចពិភាក្សាគ្នាបាន ដោយមិនពាក់ព័ន្ធនឹងពុទ្ធសាសនា ។

៦១. ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលមានចំនួនជនរងគ្រោះ ធួនល្មមដែលមាននៅក្នុងទីតាំងមួយ និង

មិនទាន់មានការកំណត់ថាតើសំណងត្រូវបានរៀបចំ និងអនុវត្តនៅឡើយទេ វាអាចជាការសំណូមពរទៅដល់អាជ្ញាធររដ្ឋាភិបាលដើម្បីឲ្យមានការឯកភាពអំពីទីកន្លែងដែលត្រូវសាងសង់ចេតី ឬក៏ស្តូបទាំងនេះ។ យើងកំពុងតែរៀបចំនូវគម្រោងដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះដែលបានជួបជាមួយនឹងអភិបាលខេត្តមួយចំនួន ដែលអភិបាលខេត្តទាំងនោះមានបំណងផ្តល់នូវទីតាំងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់សម្រាប់ការសាងសង់ស្តូបទាំងនេះ ឬក៏ចេតី។

៦២. ប្រភេទទីបីនៃគម្រោងគឺជាគម្រោងដើម្បីរៀបចំឲ្យមានកម្មវិធីបុណ្យនៅថ្ងៃបន្ទាប់ពីថ្ងៃចេញសាលក្រម ឬក៏នៅពេលផ្សេងទៀត។ គម្រោងទាំងនេះកំណត់អំពីការរៀបចំកម្មវិធីបុណ្យបន្ទាប់ពីសាលក្រមចូលជាស្ថាពរ វាអាចប្រមូលផ្តុំដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឲ្យគាត់លើកឡើងអំពីការឈឺចាប់ជារួមដោយសារការបាត់បង់សាច់ញ្ញាតិរបស់គាត់ឬក៏សំដែងអារម្មណ៍របស់គាត់បន្ទាប់ពីមានសាលក្រម។លើសពីនេះទៅទៀតត្រូវបានស្នើសុំឲ្យមានការរៀបចំកម្មវិធីបុណ្យនេះឡើងនៅថ្ងៃចងចាំ សម្រាប់ឆ្នាំមួយចំនួន

រយៈពេលប៉ុន្មានឆ្នាំសម្រាប់កម្មវិធីបុណ្យជាក់លាក់មួយចំនួន នៅទីកន្លែង និងពេលវេលាដែលនឹងត្រូវកំណត់នៅពេលក្រោយ។

៦៣. សំណងនេះត្រូវផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយពួកគេនឹងត្រូវទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីជាសាធារណៈ និងត្រូវផ្តល់នូវឱកាសដល់ជនរងគ្រោះ និងមនុស្សជំនាន់ក្រោយឱ្យនឹកឃើញអំពីជនរងគ្រោះនៅសម័យខ្មែរក្រហមដោយមានលក្ខណៈជាសមូហភាព។មិនទាន់មានការបញ្ជាក់កំណត់ថាតើវិធីនៃសំណងនេះត្រូវបានរៀបចំឡើង ឬក៏អនុវត្តយ៉ាងណានោះទេ។យោងតាមសំណើមួយក្នុងចំណោមសំណើផ្សេងៗទៀត អង្គភាពគាំពារជនរគ្រោះនឹងទទួលបន្ទុកក្នុងការរៀបចំកម្មវិធីដំបូងបន្ទាប់ពីមានសាលក្រម។

៦៤. គម្រោងទីបួន និងជាគម្រោងចុងក្រោយនៅក្នុងប្រភេទនេះគឺមានឈ្មោះថាគម្រោងចូលរួមក្នុងការរក្សាកន្លែងឧក្រិដ្ឋកម្ម ។ គម្រោងនេះគឺមានគោលដៅចូលរួមនៅក្នុងការរៀបចំការថែរក្សាកន្លែងឧក្រិដ្ឋកម្មដែលមាននៅក្នុងដីកាដំណោះស្រាយ និងទីកន្លែងពាក់ព័ន្ធនឹងសំណុំរឿង សំណងនេះនឹងត្រូវផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនៃទីកន្លែងឧក្រិដ្ឋកម្មទាំងអស់នោះ។ ការរក្សាទីកន្លែងឧក្រិដ្ឋកម្មទាំងនោះគឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីជាភស្តុតាងបង្ហាញឱ្យឃើញជាក់ស្តែងអំពីទីកន្លែងណាខ្លះដែលអំពើ ដ៏សាហាវព្រៃផ្សៃនេះត្រូវបានប្រព្រឹត្តឡើង។ ដើមបណ្តឹងរដ្ឋប្បវេណីអាចរំលឹកវិញ្ញាណខន្ធទៅដល់ព្រលឹងអ្នកដែលបានស្លាប់ទៅដែលជាសាច់ញ្ញាតិ ឬក៏រំលឹកទៅដល់សាច់ញ្ញាតរបស់ខ្លួនអំពីការឈឺចាប់នៅក្នុងសម័យនោះ។ លើសពីនេះទៀតការរក្សាទីកន្លែងទាំងអស់នេះជាឧទាហរណ៍ជាក់ស្តែងនៃប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាវិធានការណ៍ប្រសើបំផុតក្នុងការបង្ហាញអំពីដំណើរការរបស់របបនេះទៅដល់បុគ្គលទាំងឡាយណាដែលមិនបានដឹងអំពីប្រវត្តិសាស្ត្រទាំងអស់នេះ។

៦៥. នៅឆ្នាំ២០០២ ដោយរដ្ឋាភិបាលបានចេញសរាចរណ៍ណែនាំមួយ ដើម្បីថែរក្សាទីកន្លែងទាំងអស់នេះ។ យើងកំពុងតែធ្វើអត្តសញ្ញាណទៅសហការជាមួយអង្គភាពគាំពារជនរងគ្រោះដែលជាអ្នកបានទៅពិនិត្យ

មើលទីកន្លែងទាំងនោះជាក់លាក់ ថាតើទីកន្លែងដែលជាផ្នែកនៃដីកាដំណោះស្រាយត្រូវបានថែរក្សាដល់កម្រិតណា ហើយយើងក៏កំពុងតែពិភាក្សាពេលនេះថាតើទីកន្លែងទាំងនោះត្រូវបានថែរក្សាយ៉ាងដូចម្តេចដើម្បីឈានទៅដល់កំណត់ថាអ្វីដែលជាតម្រូវការនៅក្នុងការថែរក្សាទីកន្លែងនោះឬក៏អភិវឌ្ឍទីកន្លែងនោះជាបន្ថែមទៀត។ អង្គភាពគាំពារជនរងគ្រោះកំពុងសហការជាមួយអាជ្ញាធរសាធារណៈពាក់ព័ន្ធដើម្បីរៀបចំគម្រោងទាំងអស់នោះ។

## ខ. ប្រភេទទី២ ស្តីពីការធ្វើសំណងផ្លូវកាយ និង ផ្លូវចិត្ត

៦៦. ប្រភេទទីពីរនេះ គឺពាក់ព័ន្ធទៅនឹងវិធានការស្តារនីតិសម្បទា ហើយមានសំណងជាច្រើនដែលមានគោលដៅសម្រាប់ស្តារនូវសុខភាពផ្លូវចិត្ត៦៦ និងផ្នែកស្មារតីរបស់ជនរងគ្រោះ ឬក៏សម្រាប់ធ្វើឱ្យធូរស្បើយនូវការឈឺចាប់ដែលកើតឡើងអំពីព្យសនកម្មនៅក្នុងសម័យខ្មែរក្រហម។

៦៧. គម្រោងទី១ មានឈ្មោះថាគម្រោងបង្កើតសេវាសុខភាពផ្លូវចិត្ត និងរូបរាងកាយ។គម្រោងនេះមានគោលដៅបង្កើតសេវាសុខភាពផ្លូវចិត្ត និងសុខភាពរូបកាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងនូវការឈឺចាប់ ឬក៏មានជំងឺដោយហេតុឧក្រិដ្ឋកម្មដែលកើតមានឡើងនៅក្នុងសម័យខ្មែរក្រហម។ គម្រោងនេះមានសំណើរជាច្រើន តែនៅក្នុងនោះមានផងដែរការបង្កើតមជ្ឈមណ្ឌលសុខភាពសម្រាប់មនុស្សចាស់ ដែលរួមមានដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចាស់ ការបង្កើតមជ្ឈមណ្ឌលផ្លូវចិត្តសម្រាប់ជនរងគ្រោះ និងការចុះឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកម្មវិធីរដ្ឋដែលមានស្រាប់ដោយអនុញ្ញាតឱ្យមានកាតសម្គាល់ជនរងគ្រោះដើម្បីអាចទទួលបាននូវសេវាសុខភាពដោយចំណាយតិចតួច។

៦៨. អ្នកដែលទទួលផលប្រយោជន៍នៃគម្រោងនេះគឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងនូវការឈឺចាប់ និងបញ្ហាសុខភាពដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងសម័យនោះ។ គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ពួកគាត់តាមរយៈការថែរក្សាសុខភាពផ្លូវកាយ និងផ្លូវចិត្ត និងជួយឱ្យគាត់ធូរស្បើយនូវការឈឺចាប់។ គម្រោងទាំងអស់នេះអាចត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធ ដែលមាន

ស្រាប់ដូចជាអង្គការ TPO, SCC និងមជ្ឈមណ្ឌលសុខភាពផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយការពិពណ៌នានៃភាពជាក់លាក់នៃគម្រោងទាំងអស់នេះមិនអាចផ្តល់លើសពីនេះបានឡើយនៅពេលនេះ។

៦៩. គម្រោងទី២ នេះគឺជាគម្រោងគាំទ្រទៅដល់ក្រុមជួយគ្នាទៅវិញទៅមក។ គម្រោងនេះមានគោលដៅជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការលើកឡើងអំពីការឈឺចាប់ និងលើកតំកើនការផ្សះផ្សារ។ គម្រោងនេះរួមបញ្ចូលនូវការបង្កើតឱ្យមានបណ្តាញជាក់លាក់សម្រាប់ជនរងគ្រោះផ្នែកហិង្សាខាងយេនឌ័។ សំណាងនេះផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានបំណងចូលរួមនៅក្នុងកម្មវិធីជួបជុំគ្នាដែលពួកគាត់អាចចែករំលែកនូវអារម្មណ៍របស់ពួកគាត់ និយាយអំពីរឿងរ៉ាវរបស់គាត់ដែលនេះជាវិធីមួយដើម្បីបិទនូវរឿងរ៉ាវចាស់ ហើយឆ្ពោះទៅរកការបើកជីវិតថ្មីគម្រោងនេះអាចជួយឱ្យពួកគាត់ជំនះនូវការឈឺចាប់។ គម្រោងជួយគ្នាទៅវិញទៅមកត្រូវបានអនុវត្តរួចហើយដោយអង្គការ TPO ដូច្នេះគម្រោងទាំងអស់ដែលនឹងត្រូវបង្កើតឡើង នឹងអាចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាដើម្បីបន្តកិច្ចការទាំងអស់នោះហើយអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះចូលរួម។

## គ. ប្រភេទទី៣ ការចងក្រងឯកសារ/ការអប់រំ

៧០. ប្រភេទទី៣នេះ រួមមានគោលដៅរក្សា និងជម្រុញឱ្យមានការយល់ដឹងអំពីប្រវត្តនៅក្នុងសម័យខ្មែរក្រហម និងបទពិសោធន៍មួយៗរបស់ជនរងគ្រោះ។

៧១. គម្រោងដំបូងគឺ គម្រោងបង្កើតឱ្យមានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។គម្រោងនេះរួមមានការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហម និងឯកសារស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងកម្មវិធីជាតិរួមទាំងការកសាងមជ្ឈមណ្ឌលអប់រំផងដែរ រហូតដល់ការកសាងជាមជ្ឈមណ្ឌលអប់រំនានា។ គម្រោងនេះអាចអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីផ្ទេរនូវចំណេះដឹង និងការលើកឡើងពីឧក្រិដ្ឋកម្ម

ដែលខ្លួនទទួលរងទៅមនុស្សជំនាន់ក្រោយ ហើយបង្ហាញទៅដល់ពួកអ្នកទាំងអស់នោះនូវអតីតកាល ដែលនៅក្នុងនោះមានឧក្រិដ្ឋកម្មដែលមិនគួរត្រូវបានបំភ្លេច ឬក៏ដែលគេមិនត្រូវប្រព្រឹត្ត។ សំណងនេះនឹងបានផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ហើយនិងមនុស្សជំនាន់ក្រោយ។ វាអាចមានគោលដៅសហប្រតិបត្តិការតាមទម្រង់ជាវិភាគទានសៀវភៅ ពីរបបខ្មែរក្រហមដែល DC-CAM បានចែកចាយនៅតាមសាលារៀននានា ហើយវិភាគទានទាំងនេះ អាចអនុញ្ញាតឲ្យរៀបរាប់ពីសំណុំរឿងខ្មែរក្រហមនៅ អ.វ.ត.ក ។

៧២. **គម្រោងទី២ គឺជាគម្រោងតស៊ូមតិដើម្បីរៀបចំមជ្ឈមណ្ឌលឯកសារ** គម្រោងទាំងនេះមានគោលដៅបង្កើតឡើងនូវទីកន្លែងដើម្បីជាប្រយោជន៍ទៅដល់សាធារណជន ក្នុងការទទួលបាននូវឯកសារប្រវត្តិសាស្ត្រ សម្ភារៈផ្សេងៗដែលមាននៅក្នុងបណ្ណាសារ បណ្ណាល័យ សារមន្ទីរ សម្រាប់គោលដៅថែរក្សាសម្ភារៈទាំងអស់នេះ និង សិក្សារៀនសូត្រស្វែងយល់អំពីរបប និងដំណើការនៃសាលាក្តីខ្មែរក្រហម។ គម្រោងនេះផ្តល់ឱកាសសម្រាប់ប្រមូលផ្តុំឯកសារអំពីរបបខ្មែរក្រហម និងបង្កភាពងាយស្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវព័ត៌មានទាំងនេះ។

៧៣. មជ្ឈមណ្ឌលឯកសារមានតួនាទីក្នុងការប្រមូល រក្សា ធ្វើការវិភាគ បែងចែកឯកសារពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមសម្រាប់សារៈមន្ទីរ បណ្ណាល័យ មជ្ឈមណ្ឌលប្រហាក់ប្រហែលក្នុងគោលដៅថែរក្សាឯកសារ និង ជូនសម្រាប់អានដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមនុស្សជំនាន់ក្រោយ។

៧៤. សំណងនេះនឹងត្រូវផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងប្រជាជនកម្ពុជាជាពិសេសក្មេងជំនាន់ក្រោយ នៅក្នុងការអនុវត្តវាមិនទាន់មានការសម្រេចថាតើគម្រោងនេះនឹងបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារមួយ ឬក៏មជ្ឈមណ្ឌលឯកសារតូចៗនៅក្នុងខេត្តនានាឬយ៉ាងណានោះ? ការសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) កំពុងស្ថិតក្នុងការពិចារណាដោយសារថាយើងកំពុងពិចារណាការបង្កើតឲ្យមានសារៈមន្ទីរផងដែរ។ សំណងនេះនឹងត្រូវបានរៀបចំឡើង និង អនុវត្តដោយ

សហការជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងសហគមន៍នានានៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលអភិរក្ស និងលើកកម្ពស់ វប្បធម៌ជនជាតិចាមនានា ក៏ យើងខ្ញុំមានគោលបំណងនឹងធ្វើការស្នើសុំផងដែរ ។

៧៥. **គម្រោងទី៣ គឺជាបញ្ជីចុះឈ្មោះជនរងគ្រោះ ឬក៏ក្រាំងមាស**។គម្រោងនេះសំដៅបង្កើតឯកសារប្រវត្តិសាស្ត្រដែលរំលឹកទៅដល់ជនរងគ្រោះ ហើយដែលអ្នកជំនាន់ក្រោយអាចពិនិត្យមើលបាន។ បញ្ជីអនុញ្ញាតឲ្យមានលទ្ធភាពនៅក្នុងការកត់បញ្ចូលអំពីជនរងគ្រោះនានានៃរបបខ្មែរក្រហមច្រើនតាមតែអាចធ្វើទៅបាន ហើយអនុញ្ញាតឲ្យមានបញ្ជីធំទូលាយមួយនៃបទឧក្រិដ្ឋដែលបានកើតឡើង និងចំនួននៃជនរងគ្រោះដោយវាអាចទទួលនូវអ្នកទាំងឡាយណាដែលចង់និយាយពីរឿងរ៉ាវរបស់ខ្លួន។ បញ្ជីនេះទទួលស្គាល់ផងដែរនូវឧក្រិដ្ឋកម្មដែលជនរងគ្រោះបានទទួលរង។

៧៦. សំណងនេះនឹងផ្តល់ជាប្រយោជន៍ទៅដល់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងឡាយនៃរបបនេះដែលមានបំណងចូលរួម។ ទាក់ទងទៅនឹងការអនុវត្តរបស់វាតាមរយៈទម្រង់បញ្ជីដែលបានលើកឡើងផ្សេងៗគ្នានេះក្រុមនានាស្នើថាសៀវភៅបញ្ជីដ៏ធំទូលាយមួយនឹងបញ្ចូលនូវការរាយរាប់របស់ជនរងគ្រោះទាំងឡាយ និងអ្នកដទៃទៀត ព្រមទាំងមានបញ្ជីរបស់ជនរងគ្រោះដែលជាបញ្ជីសាមញ្ញ ហើយទាំងពីរនេះគឺមានគោលដៅដូចគ្នា។ លើសពីនេះគេបានត្រៀមថាបញ្ជីជនរងគ្រោះត្រូវរក្សានៅក្នុងទម្រង់ជាសៀវភៅសរសេរដៃព្រមទាំងជាទម្រង់តាមរយៈ Internet ផងដែរ ដោយដាក់នៅក្នុងប្រព័ន្ធតុលាការទុរនិម្មិតដើម្បីអាចឲ្យមនុស្សជាច្រើនអាចចូលពិនិត្យមើលបាន។

៧៧. គម្រោងចុងក្រោយនៃប្រភេទនេះគឺជាការចុះផ្សាយឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម វាមានគោលដៅស្នើសុំទៅដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ចូលឈ្មោះពេញរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងប្រសិនបើសុំដោយមេធាវីនាំមុខតំណាងដើមបណ្តឹរដ្ឋប្បវេណី នូវទីកន្លែងស្នាក់នៅ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងមុខងារ និងថាត្រូវទទួលផងដែរដែលនឹងត្រូវទទួលនៅក្នុង

នីតិវិធី។ លើសពីនេះទៅទៀតការចែកផ្សាយជាទូលាយពាសពេញផ្ទៃប្រទេសត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍ដល់សាធារណជននៅកម្ពុជាដើម្បីឲ្យដឹងអំពីការរកឃើញរបស់តុលាការ។ វិធានការនេះនឹងផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយវាជាការទទួលស្គាល់អំពីការចូលរួមរបស់ពួកគាត់នៅក្នុងនីតិវិធីដោយសារនេះគឺជាវិធានការមួយក្នុងចំណោមវិធានការសំណងជាច្រើនដែលមាននៅក្នុងសំណុំរឿង ០០១ វានឹងមិនអាចមានកើតឡើងនៅក្នុងការអនុវត្តករណី ០០២ បានឡើយ។

## ឃ. ប្រភេទទី៤ គម្រោងដទៃទៀត

៧៨. ចេញពីការពិគ្រោះជាមួយនឹងដើមបណ្តឹងគឺថា យើងបង្កើតចេញជាគម្រោងជាក់លាក់ ដែលថាមានការឯកភាពទាំងអស់គ្នា ហើយនិងឥឡូវនេះចូលទៅនិយមន័យអន្តរជាតិចម្បងនៃសំណង គឺបានន័យថាការរំឭកអនុស្សាវរីយ៍ ការចងចាំ ហើយនិងស្តារនីតិសម្បទា ឯកសារ ហើយនិងការអប់រំ ដែលសហភាតាខ្ញុំបាននិយាយរួចមកហើយ។ បើនៅក្បែរគម្រោងនេះគឺថាមានគម្រោងជាច្រើនទៀត ដែលយើងខ្ញុំមិនបាននិយាយថា វាមានលក្ខណៈពិសេសនោះទេ ក៏ប៉ុន្តែវាលក្ខណៈប្លែកពីគេនេះ មិនឲ្យយើងនិយាយឲ្យបានក្បោះក្បាយទេនៅពេលនេះ ដើម្បីបង្ហាញថា វាជាគម្រោងដែលថាអាចប្រភេទ ហើយនិងទ្រង់ទ្រាយនោះយើងបានកំណត់រវាងយើងរួចមកហើយ។ ដូច្នេះយើងខ្ញុំសូមនាំយកមកនូវព័ត៌មានលំអិតមួយចំនួន ដែលអាចបំភ្លឺដល់អង្គជំនុំជម្រះបាន។

៧៩. ចំណោមគម្រោងទាំងអស់នេះ គឺថាមានគម្រោងដំបូងនោះ នៅក្នុងចំណោមគម្រោងទាំងបួននោះ គឺថាមូលនិធិសំណងនោះ ដែលថាឈ្មោះ ហើយនិងចំណងជើងនោះ អាច ឬក៏ត្រូវផ្លាស់ប្តូរបាននៅពេលក្រោយ។ កថាខណ្ឌ៦៧០ នៃសាលក្រមរបស់ ឌុច អង្គជំនុំជម្រះបានប្រកាសថា ខ្ញុំសូមស្រង់ "សំណើទាំងអស់ដែលថា ទោះបីផ្ទាល់ ឬក៏ដោយប្រយោលក្តី ដែលស្នើសុំសំណងប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬការបង្កើតមូលនិធិក្នុងភារកិច្ចគ្រប់គ្រងសម្រាប់ជនរងគ្រោះមិនស្ថិតនៅក្នុងវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេចបានទេ"។ ចប់សម្រង់។ នៅលើឃរ

លើមូលដ្ឋាននេះហើយដែលអង្គជំនុំជម្រះបានបដិសេធសំណើមួយចំនួន ដែលសុំឱ្យដោយប្រយោល ឬក៏ដោយផ្ទាល់ គឺថាសុំឱ្យមានផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះបានបដិសេធសំណើមួយចំនួន ឧទាហរណ៍ដូចជាការបង្កើតការមូលនិធិសំណងជាដើមនោះ។

៨០. អង្គជំនុំជម្រះបានលើកឡើងថា សំណងហិរញ្ញវត្ថុមិនអាចធ្វើឡើងបានឡើយ ទោះបីជាឯកជនឬក៏សមូហភាពក្តី ក៏ប៉ុន្តែចំពោះយើងខ្ញុំវិញ យើងដឹងពីដែនកំណត់នេះ ហើយបើនិយាយឱ្យត្រង់តែម្តងទៅ គឺថាយើងគិតថាវាមានមូលហេតុ មូលហេតុនេះគឺថា វាដោយសារចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនពេក។ លើសពីនេះទៀតនោះគឺថា លក្ខណៈសមូហភាពនៃសំណងមានតម្លៃ វាសំខាន់ណាស់នៅក្នុងការជម្រះសេចក្តីនេះ ហើយខ្ញុំសូមលើកឡើងម្តងទៀត គឺថាមិនមែនថាត្រឹមតែចំនួនដើមបណ្តឹងរដ្ឋប្បវេណី ៣៩០០នាក់នោះទេ គឺថាប្រជាជនកម្ពុជាទាំងមូលតែម្តង។ គឺដោយសារទំហំនៃព្យសនកម្មសមូហភាព ហើយនិងអត្ថន័យជានិមិត្តរូបនៃសំណងដែលនឹងផ្តល់ជូននេះហើយ ដែលជាមូលហេតុនៃការបង្កើតមូលនិធិសំណងជំងឺចិត្តនោះ។

៨១. ដូច្នេះ យើងអាចហៅគម្រោងនេះបានថា គម្រោងបង្កើតមូលនិធិសំណងដែលនឹងផ្តល់ហិរញ្ញប្បទានដល់សំណងផ្លូវចិត្ត និងសមូហភាព។វិធានផ្ទៃក្នុងបានចេញវិធានការចែងអំពីហិរញ្ញវត្ថុសំណង ដែលជាលក្ខណៈនិមិត្តរូប ហើយនិងផ្លូវចិត្តនេះ។ អ៊ីចឹងហើយបានជាមាត្រា២៣ស្ទួនបួន (៣)(ខ) នេះតម្រូវឱ្យការធានាផ្នែកហិរញ្ញវត្ថុនៃគម្រោងត្រូវផ្តល់ជូនដល់អង្គជំនុំជម្រះនៅក្នុងសំណើសំណងចុងក្រោយនោះ។ ដូច្នេះវាជាការសមហេតុសមផលក្នុងការបង្កើតគម្រោងមូលនិធិសំណង ឬក៏ថាជាអង្គការផ្តល់ហិរញ្ញប្បទាននោះ។ អង្គការនេះគឺថាធ្វើឱ្យអ្នកផ្តល់មូលនិធិដែលថា ទុកចិត្តក្នុងការដាក់មូលនិធិទៅនឹងអង្គការឯករាជ្យមួយ ដែលប្រមូលអ្វីដែលថាអាចធ្វើឱ្យសម្រេចគម្រោងទាំងឡាយនេះបាន។

៨២. មានមូលនិធិសំណងជាច្រើន ឧទាហរណ៍ទីមួយ គឺថាឧទាហរណ៍របស់ តុលាការព្រហ្ម ទណ្ឌ អន្តរជាតិ អង្គជំនុំជម្រះប្រហែលជាអាចជំទាស់ថា អង្គការនេះគឺថាបង្កើតឡើងដោយលក្ខន្តិកៈរ៉ូម នៅក្នុងពេល

ដែលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយជាអង្គការដែលនៅក្នុងចំណុះតុលាការនោះផ្ទាល់តែម្តង។ យើងមិនមានករណីនេះនៅ អ.វ.ត.ក នោះទេ ក៏ប៉ុន្តែមិនមានអ្វីដែលរាំងស្ទះមិនឲ្យបង្កើតមូលនិធិនេះ ក្រោមទម្រង់ណាមួយផ្សេងទៀត ធ្វើយ៉ាងណាដើម្បីឲ្យធានានូវការប្រើប្រាស់មូលនិធិយើងប្រមូលបាន។ ឧទាហរណ៍មួយទៀត គឺថាអាចជាមូលនិធិសហព័ន្ធអាឡឺម៉ង់ ដែលគោលបំណងគេនោះ គឺថាវាមានហួសពីការប្រមូលមូលនិធិ ឬក៏ការប្រើប្រាស់មូលនិធិនោះទៅទៀត។ ឧទាហរណ៍ច្រើនទៀតដែលយើងអាចលើកមកបង្ហាញបាន ដែលចេញមកពីរឿងកាត់ក្តីផ្សេងៗទៀត ឧទាហរណ៍ដូចជារឿងកាត់ក្តីនៅតុលាការអន្តរអាមេរិកកាំងសិទ្ធិមនុស្សនោះ ដែលមាននៅក្នុងកម្រិតផ្ទៃក្នុង។ នេះជាឧទាហរណ៍មួយដែលបង្ហាញថា អង្គការមួយដែលសឹងតែរដ្ឋបាលសុទ្ធ ដែលធ្វើការក្នុងការអនុវត្ត ឬក៏ថាជាគណៈកម្មាការពិគ្រោះ ឬក៏អង្គការដែលថាមានឈ្មោះខុសពីនេះទៀត ដែលអាចចូលរួមវិភាគទានក្នុងការផ្តល់ហិរញ្ញប្រទាន ដើម្បីសម្រេចសំណងស្មុគស្មាញ ដែលថាតម្រូវឲ្យមានការចំណាយការប្រើប្រាស់ថវិកានោះ។

៨៣. យើងសុំឲ្យមានគម្រោងបែបនេះ ដើម្បីអនុវត្តសំណង។ យន្តការដែលយើងនេះ គឺថាយើងចង់បង្កើតនេះ គឺថាវានៅមានជាគម្រោងនៅឡើយទេ យើងយល់អំពីឧបសគ្គផ្លូវច្បាប់ដែលថាមិនអាចឲ្យអង្គជំនុំជម្រះអនុញ្ញាតធ្វើរបៀបនេះបាន។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី គម្រោងបែបនេះ គឺថាអាចឆ្លើយតបនឹងសំណួរមួយដែលចោទឡើងដោយថា តើយើងត្រូវធានាការសម្រេចគម្រោងសំណងពិតប្រាកដយ៉ាងម៉េចបាន បើយោងទៅតាមឧបសគ្គផ្នែកសម្ភារៈដ៏សម្បើមនោះ?

៨៤. គម្រោងនេះ គឺជាចម្លើយដ៏ច្បាស់លាស់មួយ ដែលឆ្លើយតបទៅនឹងការសិទ្ធិទទួលសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអាចធ្វើឲ្យយើងសម្រេចបាននូវគម្រោងជាច្រើន ហើយដើម្បីប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី ដែលថានឹងទទួលប្រយោជន៍ពីគម្រោងទាំងអស់នេះ។ ហើយក្រៅពីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺថាមានជនរងគ្រោះទាំងអស់តែម្តងដែលអាចទទួលប្រយោជន៍បានពីនេះ ព្រោះថាវាមានលក្ខណៈទូលំទូលាយ។ អ៊ីចឹងគិតថា ពាក្យថា សមូហភាព វាអាចឲ្យយើងយល់ឃើញថា ជនរងគ្រោះទាំងមូលតែម្តងដែលអាចទទួលប្រយោជន៍ពីនេះបាន។

៨៥. គម្រោងទីពីរនៃប្រភេទនេះ គឺថាគឺជាដៃគូមូលនិធិសំណង ដែលសំណងនៃអង្គការផ្តល់ហិរញ្ញប្រទាននេះ គឺជាគម្រោងដែលគម្រោងបង្កើតអង្គការសម្រាប់ត្រួតពិនិត្យការអនុវត្តសំណង បន្ទាប់ពីការប្រកាសសាលក្រម ហើយនិងផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសហគមន៍អន្តរជាតិ ស្តីអំពីការអនុវត្តគម្រោងសំណងនេះ។ បើយើងដឹងណាស់ថា អង្គការនេះគឺថាត្រូវមានហិរញ្ញប្រទាន រកហិរញ្ញប្រទានដោយខ្លួនឯង ហើយនិងពិបាកអនុវត្ត ក៏ប៉ុន្តែវាមិនមែនថាមិនអាចធ្វើទៅកើតនោះទេ។

៨៦. ហើយកង្វល់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាត្រូវធានាយ៉ាងណាដើម្បីគឺថា សំណងទាំងអស់ដែលនឹងផ្តល់ជូននោះត្រូវបានអនុវត្តដោយពិតប្រាកដ។ យើងដឹងថាអង្គជំនុំជម្រះនឹងមិនអាចផ្តល់សំណង ឬក៏ថាការអនុវត្តសំណងបានទេនៅពេលដែលថាតុលាការនេះបិទទ្វារទៅនោះ។ គ្រាន់តែផ្ទុយទៅវិញ អង្គការឯករាជ្យមួយនឹងធានាថាធ្វើយ៉ាងណា ដើម្បីឲ្យការអនុវត្តសំណងនេះនឹងសម្របសម្រួល បើសិនជាអាចមានបាន គឺថាក្នុងការអនុវត្តសំណងនៅពេលក្រោយ។

៨៧. ដូច្នេះដែលបេសកកម្មអន្តរជាតិ លក្ខណៈជាតិ និងអន្តរជាតិ អង្គការនេះអាចអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះ និងសហគមន៍អន្តរជាតិដឹងអំពីការវិវត្តនៃសំណងនីមួយៗ។ សំណងមួយភាគនោះនៅក្នុងការប្រកាសសាលក្រម ហើយមួយភាគទៀតមាននៅក្នុងការសម្រេចដ៏ពិតនៃគម្រោងនេះ ហើយភាគទៀតគឺថានៅក្នុងការដែលថាយើងផ្តល់ព័ត៌មានពីសំណងនេះទៅអ្នកផ្សេងទៀតដែលថាក្រៅពីអ្នកដែលទទួលសំណងនេះ។

៨៨. គម្រោងទីបី នៃប្រភេទនេះគឺគម្រោងដែលអាចយើងថា ដាក់ឈ្មោះបានថាគម្រោងសម្របសម្រួលនៃការផ្តល់សញ្ជាតិខ្មែរ ខ្ញុំនិយាយថាប្រើពាក្យសម្រួលទេ។ អ៊ីចឹងបានន័យថា គឺថានេះចំណងជើងនេះគឺថាយើងដាក់ឲ្យហ្នឹងគឺថាវា ដាក់មិនសមស្របដែលថាលឿនពេក នៅក្នុងសវនាការបឋម។ គម្រោងនេះមានចំណងជើងថាផ្តល់សញ្ជាតិវៀតណាមទៅដល់ខ្មែរ-- ខ្មែរដល់វៀតណាម ហើយអង្គជំនុំជម្រះនៅក្នុងអនុស្សរណៈរបស់ខ្លួនបានធ្វើការកត់សម្គាល់ អង្គជំនុំជម្រះថា អង្គជំនុំមិនអាចបង្ខំរដ្ឋាភិបាលឲ្យផ្តល់សញ្ជាតិកម្ពុជាឲ្យវៀតណាមនោះទេ។មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ពីព្រំដែនកំណត់នេះ។

៨៩. ដើម្បីឱ្យច្បាស់នៅថ្ងៃនេះតែម្ដងគឺថា ទម្រង់សំណងដែលជនជាតិវៀតណាមដែលរួចផុតពីឧក្រិដ្ឋកម្មនៅប្រទេសកម្ពុជានោះ ថាមិនមែនមិនចង់រំលោភលើអំណាច ឬក៏អាជ្ញាធររបស់រដ្ឋាភិបាលកម្ពុជានោះទេទាក់ទងទៅនឹងការផ្ដល់សញ្ជាតិនេះ។ដូច្នេះយើងខ្ញុំសូមថាការសំណូមពររបស់យើងនេះគឺវាលក្ខណៈស្របច្បាប់ដោយសារគាត់ទទួលព្យសនកម្មដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការជម្លៀសដោយបង្ខំដោយវៀតណាមចេញ ដេញវៀតណាមចេញពីប្រទេសកម្ពុជាជាដើម។ដូច្នេះហើយផលវិបាកនៃការជម្លៀសវៀតណាមចេញពីប្រទេសកម្ពុជា នេះគឺថាបណ្ដាលឱ្យគាត់បាត់លិខិត ឬក៏អត្តសញ្ញាណប័ណ្ណអីជាដើម។ អ៊ីចឹងផលវិបាកនេះគឺថាយើងអាចដោះស្រាយដោយគម្រោងដែលថាយើងផ្ដល់សញ្ជាតិឱ្យជនជាតិវៀតណាមនេះ ដែលថាគម្រោងនេះវាស្ថិតនៅក្នុងគម្រោងសំណងសមូហភាព ហើយនិងតាមផ្លូវចិត្តដែលស្ថិតនៅក្នុងអាណត្តិរបស់ អ.វ.ត.ក។

៩០. វិធានការសំណងនេះគឺជាគម្រោងដែលសម្រាប់សម្របសម្រួលសុំសញ្ជាតិកម្ពុជាពីសំណាក់វៀតណាមដែលទទួលរងនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហមដូចជាការបណ្ដេញចេញពីប្រទេសកម្ពុជាហើយដែលថា គាត់ទាំងអស់គ្នានោះបាត់អត្តសញ្ញាណប័ណ្ណ ឬក៏បាត់មធ្យោបាយនៅក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណប័ណ្ណរបស់គាត់ ឬក៏បំបាត់ទំនាក់ទំនងរបស់គាត់ជាមួយនឹងទឹកដីកម្ពុជា អ្នកខ្លះនោះកើតឡើងនៅប្រទេសកម្ពុជា ដែលជីដូនជីតាមកបន្សល់។ ដូច្នេះបន្ទាប់ពីការជម្លៀសគាត់ចេញពីប្រទេសខ្មែរទៅដោយពួកខ្មែរក្រហមនោះ ជនរងគ្រោះទាំងនោះមិនអាចដឹងថាគាត់ៗនៅស្រុកខ្មែរប៉ុន្មានឆ្នាំ ហើយឯកសារអីទាំងឡាយមានទំនាក់ទំនងជាមួយជីដូនជីតា។ ហេតុនេះ បានន័យថាគាត់បានទទួលព្យសនកម្មបន្ថែមទៀត គឺថាដែលគាត់មិនអាចទទួលបានការផ្ដល់សញ្ជាតិខ្មែរនោះ អនុលោមតាមច្បាប់ជាតិ ជនរងគ្រោះទាំងអស់នេះគឺថាប្រឈមមុខទៅនឹងហានិភ័យពិតប្រាកដដែលថាខ្លួននឹងអាចរស់ដោយគ្មានសញ្ជាតិ ហើយនឹងរស់នៅក្រៅសង្គមដោយមិនដែលបានប្រព្រឹត្តកំហុសអ្វីទាស់តែសោះ។

៩១. ហេតុនេះការសម្របសម្រួលនៃការផ្ដល់សុំពាក្យសុំសញ្ជាតិនេះគឺថា ឧទាហរណ៍អាចដូចជា ជាគម្រោងគឺថាលើកកម្ពស់ឱ្យយល់ពីច្បាប់ អំពីសញ្ជាតិរបស់ប្រទេសកម្ពុជា ហើយនិងលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់នានាដែលខ្លួនចង់សុំបំពេញ អនុលោមទៅតាមនីតិវិធីកម្ពុជានោះ។ គម្រោងមួយទៀតដែលពាក់ព័ន្ធ

គឺថាអាចបង្កើតទៅជាសេវាផ្លូវ សេវាកម្មច្បាប់ដែលស្ថិតនៅក្នុងកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់នោះនៅ ហើយដែលទៅជួយឲ្យប្រមូលឯកសាររបស់អ្នកដែលដាក់ពាក្យសុំទាំងអស់ ហើយ និងជួយដល់បេក្ខជនទាំងអស់នោះដែលធ្វើពាក្យសុំនោះ ហើយនឹងយើងដាក់ជូនសំណុំពាក្យសុំទាំងអស់ នេះទៅស្ថាប័នរដ្ឋកម្ពុជានោះ។ អ៊ីចឹង គឺថាយើងអាចថាឲ្យមានសម្របសម្រួលជាមួយនឹងអាជ្ញាធរ រដ្ឋាភិបាល ដើម្បីឲ្យគាត់អាចដឹងដំណឹងអំពីច្បាប់ អំពីស្ថានភាពរបស់ជនជាតិវៀតណាមទាំងអស់នេះ និងឲ្យអាជ្ញាធរនេះគាត់ធ្វើដោយអនុលោមតាមច្បាប់ជាតិស្តីអំពីសញ្ជាតិ ហើយនិងគាត់អាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការសម្រេចថា តើផ្តល់សញ្ជាតិឲ្យជនជាតិវៀតណាមនេះ ឬក៏អត់នោះ?

៩២. ពាក្យសុំ សញ្ជាតិខ្មែរណាមួយដែលកើតឡើងពីសំណើសុំទាមទារសំណងមួយ ឬក៏វិធានដែលផ្តល់សំណងដោយ គេប្រមើមើលពាក្យសុំដែលធ្វើសម្រេចដោយរដ្ឋ អាជ្ញាធរកម្ពុជា។ គម្រោងនេះសំដៅត្រឹមតែសម្រួលដំណើរការប្រព្រឹត្តទៅនៃការស្នើសុំសំណង ហើយអាជ្ញាធរកម្ពុជានឹងកំណត់លក្ខន្តិកៈលើរបស់អ្នកសុំទាំងអស់នេះទៅតាមនីតិវិធីធម្មតា។

៩២. វានឹងគួរតែចៀសវាងនូវការមិនយល់គ្នាច្បាស់លាស់អំពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ឬក៏ពីសាធារណៈជន ឬក៏ពីសំណាក់ប្រជាជនកម្ពុជាទាំងមូលតែម្តង ទាក់ទងទៅនឹងសំណើសុំសំណងដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាមនេះ។ ដើម្បីចៀសវាងកុំឲ្យ ថាឲ្យមានការរើសអើងដែលអាចជះឥទ្ធិពលអាក្រក់ទៅលើក្រុមជនជាតិវៀតណាមនេះ។ ដូច្នេះ ភាពស្របច្បាប់នៃការសុំសំណងនេះ ស្ថិតនៅ-- ផ្អែកទៅលើ គឺថាទំនាក់ទំនងដែលមិនអាចជំទាស់បានទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តហើយនិងព្យសនកម្មដែលទទួលរង។ ហើយអ៊ីចឹងគម្រោងនេះ អាចជាទម្រង់នៃសំណងមួយដ៏មានន័យចំពោះដើមបណ្តឹងរដ្ឋប្បវេណីជនជាតិ វៀតណាម។

៩៤. គម្រោងទីបួន ហើយដោយខ្លី គម្រោងទីបួននៃគម្រោងចុងក្រោយនេះ គឺថា ជាគម្រោងដែលយើងអាចដាក់ចំណងជើងបានថា គម្រោងកំណត់តម្រូវការហើយនិងបំណងប្រាថ្នាពាក់ព័ន្ធនឹងមុខរបរវិជ្ជាជីវៈ។ គម្រោងកំណត់តម្រូវការហើយនិងបំណងប្រាថ្នាពាក់ព័ន្ធនឹងមុខរបរវិជ្ជាជីវៈនេះផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការរៀបការដោយបង្ខំ ហើយអ្នកខ្លះកើតនៅពេលក្រោយនៅពេលដែល

ខ្មែរក្រហមធ្លាក់ពីអំណាចទៅនោះ។ ជាការកំណត់តម្រូវការ ហើយនិងសេចក្តីប៉ងប្រាថ្នាទាំងអស់នេះ នឹងធ្វើនៅជាមួយនឹងកុមារទាំងអស់ដែលពាក់ព័ន្ធ អ៊ីចឹងក្រុមការងារនឹងបង្កើតទៅតាមតំបន់នីមួយៗ ហើយនិងនៅក្នុងផ្នែកសំខាន់ៗនៃការបណ្តុះបណ្តាលនោះ។ រដ្ឋាភិបាលអាចថាជាសមាជិកនៃក្រុមនេះដែរ ប្រសិនជារដ្ឋាភិបាលគាំទ្រគំនិតរបស់យើងខ្ញុំ ។ បើពុំដូច្នោះទេ ការផ្តល់ហរិញ្ញប្រទានពីខាងក្រៅ គឺជាការចាំបាច់។

៩៥. អ្វីដែលទាក់ទងទៅនឹងការអនុវត្តនោះ រដ្ឋាភិបាលនឹងត្រូវបានអញ្ជើញមកជាមួយក្រុមការងារ ហើយយើងនឹងផ្តល់អំពីលទ្ធផលដល់រដ្ឋាភិបាល។ អ៊ីចឹងការបណ្តុះបណ្តាលក្រុមវិជ្ជាជីវៈនេះនឹងមានរយៈពេលមួយឆ្នាំ ហើយការផ្តល់ហិរញ្ញប្រទានត្រូវតែអាចជួយផ្តល់ថវិកាដល់គ្រូ។ បន្ទាប់ពីបញ្ចប់គម្រោងបណ្តុះបណ្តាល ក្រុមការងារនឹងជួយបុគ្គលទាំងអស់នោះឲ្យរកការងារបាន ហើយនឹងជួយគាត់នៅក្នុងកិច្ចការរកស៊ីរបស់គាត់។ មីក្រូឥណទានក៏អាចផ្តល់ជូនពួកគាត់ពាក់ព័ន្ធនឹងគម្រោងនេះ ។

៩៦. ដើម្បីបញ្ចប់លើប្រភេទចុងក្រោយនេះ យើងខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះថា លក្ខណៈពិសេសនៃគម្រោងទាំងអស់នេះមិនអាចឲ្យយើងទាំងអស់គ្នា រវាងយើងនឹងយើងនេះពិភាក្សាឲ្យបានលម្អិតទៅលើគម្រោងទាំងអស់នេះទេ។ គឺថាមានការពិភាក្សាគ្នារវាងមេធាវីទាំងអស់ ហើយនឹងយើងត្រូវតែពិភាក្សាលម្អិតតទៅទៀតនៅថ្ងៃអនាគត នៅក្នុងក្របខ័ណ្ឌនៃការពិគ្រោះ ហើយនិងការស្វែងរកកិច្ចព្រមព្រៀងឯកច្ឆន្ទមួយរវាងគ្នាយើងទាំងអស់គ្នានេះ។ នេះមិនមែនដើម្បីឲ្យធ្វើយ៉ាងណាដើម្បីឲ្យយើងអាចអនុវត្តបាន។ ហើយដូចដែលយើងសព្វថ្ងៃនេះស្ថិតនៅក្នុងដំណាក់កាលពិភាក្សា។ យើងផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានទាំងអស់នេះ អ៊ីចឹងយើងខ្ញុំសូមថាឲ្យអង្គជំនុំជម្រះជួយវាយតម្លៃ ហើយនិងលក្ខណៈចាំបាច់ជានិមិត្តរូបនៃគម្រោងទាំងនេះ ក៏ប៉ុន្តែយើងក៏មិនបំភ្លេចដែរអំពីឧបសគ្គដែលអាចមាននៅពេលដែលយើងអនុវត្តនូវគម្រោងទាំងអស់នេះ ហើយយើងនឹងព្យាយាមជំនះឧបសគ្គនេះឲ្យបាន។

**សេចក្តីសន្និដ្ឋាន**

៩៧. ជាចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍ផ្ទាល់មាត់នេះ យើងខ្ញុំសង្ឃឹមថាបាននាំមកនូវការបញ្ជាក់នានា និង ភាពលម្អិតដល់អង្គជំនុំជម្រះ ហើយដែលអាចឆ្លើយបានចំពោះអ្វីដែល អង្គជំនុំជម្រះ កំពង់ទន្ទឹងរង់ចាំ ។ យើងក៏សង្ឃឹមផងដែរថា បានពន្យល់ច្បាស់លាស់នូវបញ្ហាដែលយើងខ្ញុំជួបប្រទះ បញ្ហាដែលជាចំណោទបញ្ហាសម្រាប់យើងខ្ញុំ ហើយដោយមានជាអាទិ៍ដូចជាចេញពីការបំបែកដំណើរការនីតិវិធី ភាពមិនច្បាស់លាស់ទាក់ទងនឹងសញ្ញាណខ្លះៗ និងការកំណត់និយមន័យពាក់ព័ន្ធនឹងសំណង ។

៩៨. ខ្លឹមសារជាក់លាក់ជាបឋមស្តីពីសំណងរបស់យើងទាំងនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបនឹងបទឧក្រិដ្ឋនានាដែលបានកើតឡើងទាំងអស់តែម្តង និង ផ្តល់ដល់គ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ការបំបែកនីតិវិធីកែប្រែបញ្ហាសំណង និងនាំឲ្យយើងខ្ញុំមានភាពលំបាកក្នុងស្ថានភាពមិនច្បាស់លាស់ ។ ក្នុងក្របខណ្ឌនៃសេចក្តីសន្និដ្ឋានទូទៅនេះ យើងខ្ញុំមានបំណងនឹងចោទសួរសំណួរទូលាយមួយចំនួន ដល់អង្គជំនុំជម្រះដើម្បីឆ្លើយតបនៅពេលក្រោយ៖តើអង្គជំនុំជម្រះយល់យ៉ាងម៉េចអំពីការចង្អុលបង្ហាញដំបូងបឋមរបស់យើងនេះ ពាក់ព័ន្ធទៅនឹងការបំបែកសំណុំនីតិវិធីនេះ? តើអង្គជំនុំជម្រះយល់ឃើញយ៉ាងណាអំពីការសុំសំណងខ្លឹមសារសំខាន់ចម្បងរបស់អង្គជំនុំជម្រះ? តើអង្គជំនុំជម្រះបានកំណត់លក្ខណៈពិសេសយ៉ាងម៉េចចំពោះគម្រោងរបស់យើងនីមួយៗនេះ? នេះគឺជាសំណួរដែល មួយក្នុងសំណួរផ្សេងៗទៀតដែលថាជាការងារយើងនៅពេលក្រោយនោះយើងត្រូវធ្វើ។

៩៩. នៅទីបញ្ចប់យើងចង់បន្ថែមពីរបីម៉ាត់ដូចតទៅនេះ៖

សំណងមិនមែនត្រឹមតែជាវិធានការបច្ចេកទេសនោះទេដែលថា ធ្វើឡើងដោយគ្មានបេះដូងហើយដែលថាធ្វើទៅដែលអាចសម្រេចបានទេ។ ក៏ប៉ុន្តែត្រូវតែបំពេញចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើយ៉ាងណាដើម្បីឲ្យគាត់មានអារម្មណ៍ថា គាត់បានទទួលសំណងដែលថាធ្វើយ៉ាងណាសំណង ដែលអាចឲ្យគាត់បន្ថយការឈឺចាប់បាន។ គឺថានេះជាការពិតណាស់ពីព្រោះថា ការជម្រះសេចក្តីនេះគឺត្រូវតែបំបែកចេញជាផ្នែកតូចៗ ហើយពេលខ្លះហ្នឹងត្រូវផ្តាច់ ដកដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនចេញ។អ៊ីចឹង សំណងត្រូវតែធ្វើយ៉ាងណាឲ្យ គិតយ៉ាងណាធ្វើឲ្យហួសពីអ្វីដែលស្រួលធ្វើ ហើយដែលមិនមានតម្លៃសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណងមិនមានតម្លៃអ្វីនោះទេ បើសិនជាដើមបណ្តឹងរដ្ឋប្បវេណីយល់ថាគ្មាន

ន័យ ហើយនិងគ្មានឥទ្ធិពលអ្វីទាំងអស់សម្រាប់ខ្លួននោះ។ អង្គបុរេជម្រះ I នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងថា "ការជោគជ័យរបស់តុលាការមួយគឺជាការជោគជ័យនៃប្រព័ន្ធសំណងរបស់តុលាការនោះក្នុងកម្រិតណាមួយ"[24]។ ហេតុនេះ យើងគាំទ្រគំនិតរបស់តុលាការនេះ។

១០០. យើងដឹងថា យើងដូចជាលោភលន់ពេកហើយនៅថ្ងៃនេះ ដែលថាយើងបង្កើតគម្រោងជាច្រើន ដែលថាការលំបាកជាច្រើនដែលយើងនឹងប្រឈមនៅថ្ងៃក្រោយនោះ ក៏ប៉ុន្តែជាកាតព្វកិច្ចរបស់យើងដែលថាយើងត្រូវតែមានការលោភលន់បែបនេះ បើយើងមិនលោភលន់ទេយើងក៏មិនអាចជាអ្នកការពារដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ។ក៏ប៉ុន្តែយើងដឹងថាគម្រោងមួយចំនួននឹងត្រូវកែប្រែហើយនិងបោះបង់ចោលក៏មានដែរហើយនិងខ្លះទៀតគឺថាកែប្រែទៅតាមវិធានការក្រៅផ្លូវតុលាការ។ឥឡូវនេះយើងកំពុងតែធ្វើហើយជាសិទ្ធិរបស់យើងក្នុងការធ្វើនេះ សិទ្ធិរបស់យើងតែមួយគត់។

១០១. ប្រសិនជាយើង មានបន្ទុកក្នុងការបង្ហាញសំណងក្នុងការអនុវត្ត ដែលថាត្រូវតែអាចធ្វើទៅបាននោះ យើងមានទំនួលក្នុងការបង្ហាញគម្រោងដែលយើងថាយើងវាស់ពីកម្រិត ដែលថាធ្វើបានឬមិនបាននោះ។ ក៏ប៉ុន្តែ ទន្ទឹមនឹងនោះ អង្គជំនុំជម្រះក៏មានទំនួលខុសត្រូវក្នុងការស្វែងរកឲ្យលើសពីអ្វីដែលងាយស្រួលសម្រេចបាន។ ខ្ញុំសូមអភ័យទោសដែលខ្ញុំប្រើពាក្យថា "វាងាយស្រួលនោះ" គឺថាត្រូវរកវិធានការណាដែលថាវាត្រូវគោរពច្បាប់ ហើយក៏ប៉ុន្តែទន្ទឹមនឹងនោះគឺថា ធ្វើយើងយ៉ាងម៉េចឲ្យការផ្តល់សំណងនោះវាមានលក្ខណៈជាក់ស្តែង។

១០២. អ្វីដែលជាសំណងក្នុងសំណុំរឿងនេះគឺជាផ្លែផ្កានៃការខិតខំប្រឹងប្រែង និងឆន្ទៈរួមរបស់យើងខ្ញុំក្នុងការផ្តល់សំណង ដែលមិនមែនគ្រាន់តែជាកាយវិការ គ្មានខ្លឹមសារជ្រាលជ្រៅ បង្កឲ្យមានភាពជូរចត់ និងការខកចិត្តទៀតនោះទេ។ យើងមានកាតព្វកិច្ចធ្វើយ៉ាងណាដើម្បីឲ្យសាលក្រមដែលនឹងចេញនោះគឺថានិមិត្តរូបដ៏មានអំណាច យើងទុកចិត្តអង្គជំនុំជម្រះក្នុងការសម្រេចលើសំណងនេះ។

---

[24] នៅក្នុងរឿងក្តី សហព្រះរាជអាជ្ញា លុំបង់ហ្កា បានប្រកាសក្នុងសាលក្រមមួយចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ (សំណុំរឿង លេខ ICC-01/04-01/06) វាក្យខណ្ឌ ១៣៦ ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ១២ មីនា ២០១២ | **ពេជ អង្គ**<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |